ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មាគមបុគ្គលិកសិក្សាខ្មែរ

ទស្សនាវដ្ដី

១៤

# គ្រូបង្រៀន



ខែ មករា - កុម្ភៈ - មីនា ឆ្នាំ ២០០៣

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

ទូរស័ព្ទ : ០២៣ ២១៦ ១៨៤

# មាតិកា

**I. គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ុន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ មិត្ត
- លោកជំទាវ ប៉ែន ណារុណ
- លោក ថោង បូរ៉ាន់
- លោក កៅ ធឿន
- លោកស្រី ប្រាក់ សុធីដា
- លោកស្រី ទន់ សុគុំ
- លោក ប៉ែន សារុន
- សមាជិក សមាជិកា ស.ប.ស.ខ

**II. គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ ស៊ីរី
- លោកបណ្ឌិត អ៊ុម កុច
- លោក ស៊ិន ស៊ីម
- លោក សួង សារុន
- លោក ស៊ុង វ៉ាន់ថន

**III. វិចិត្រករ**

លោក ប៉ាន់ ត្រា

**IV. ការីកុំព្យូទ័រ**

ក.ម៉ៅ សុធី

**<u>គ្របខាងក្រៅ</u>**

- ពីមុខ : សម្តេច ហ៊ុន សែន សម្ភោធផ្ទះគ្រូបង្រៀននៅខេត្តសៀមរាប(២៦-ធ្នូ-២០០១)
- ពីក្រោយ : ផ្ទះគ្រូបង្រៀននៅខេត្តសៀមរាប


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | អារម្ភកថា | ១ |
| ២ | វិចារណកថា | ៣ |
| ៣ | ជីវប្រវត្តិសង្ខេបព្រឹទ្ធាចារ្យ យ៉ង់ ធី | ៤ |
| ៤ | បំណែងចែកភារកិច្ចគណៈកម្មាធិការនាយក ស.ប.ស.ខ អាណត្តិទី ៨ | ៧ |
| | **រាជកិច្ច** | |
| ៥ | សេចក្តីដកស្រង់ព្រះរាជក្រឹត្យ | ៨ |
| ៦ | សេចក្តីដកស្រង់អនុក្រឹត្យ | ១៤ |
| | **ទស្សនៈទូទៅ** | |
| ៧ | កំណើនប្រជាជនឆាប់រហ័ស | ១៦ |
| ៨ | ការស្រុតចុះសីលធម៌របស់សិស្សជំទង់ក្នុងសង្គមសព្វថ្ងៃ | ១៨ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៩ | វដ្តជីវិត | ២០ |
| ១០ | បច្ចេកទេសចោទសួរ | ២២ |
| | **វិជ្ជាសិក្សា និងគរុកោសល្យ** | |
| ១១ | លំហាត់បុរេសិក្សា | ២៤ |
| ១២ | ល្បិចនៃវិចារ | ២៧ |
| ១៣ | គណិតវិទ្យា : អភិវឌ្ឍន៍មេរៀន | ៣០ |
| ១៤ | វេយ្យាករណ៍ : កិរិយាហេតុ | ៣៣ |
| ១៥ | គំនូរ : វិធីបង្រៀនគំនូរ | ៣៧ |
| ១៦ | ប្រវត្តិវិទ្យា : អត្ថបទជំនួយ | ៤៤ |
| | **កំណាព្យ និងកំសាន្ត** | |
| ១៧ | ការស្រាវជ្រាវទ្រង់ទ្រាយផ្សេងៗ | ៤៦ |
| ១៨ | ចំណោទត្រិះរិះ | |
| ១៩ | បុណ្យអុំទូក ( កំណាព្យ ) | ៤៧ |
| ២០ | មោហាគតិ ( កំណាព្យ ) | ៤៨ |
| | **វេទិកាស្វែង** | |
| ២១ | យល់ដឹងពីសំនេរលេខដោយបន្ថែមសូន្យ | ៤៩ |
| | **ពត៌មាន** | |
| ២២ | ផ្ទះគ្រូបង្រៀននៅខេត្តសៀមរាប | ៥០ |
| ២៣ | តើអ្នកគ្រូ លោកគ្រូមានជីវិតទេ ? | ៥១ |
| ២៤ | ស្ថិតិសពសមាជិក និង គ្រួសារសមាជិក ចាប់ពីឆ្នាំ ១៩៩៥ ដល់ ដំណាច់ខែ ធ្នូ ឆ្នាំ ២០០២ ។ | ៥២ |

# អារម្ភកថា

លោកគ្រូ អ្នកគ្រូ ជាទីគោរពរាប់អាន !

ថ្ងៃនេះ "ទស្សនាវដ្ដីគ្រូបង្រៀន" បានវិលមកជួបប្រិយមិត្តជាទីមេត្រី ដោយក្ដីទីករលឹកយ៉ាងក្រៃលែង និងសូមប្រសិទ្ធពរជ័យសិរីមង្គលមហាប្រសើរ ជូនចំពោះលោកគ្រូ អ្នកគ្រូក្នុងឱកាសឆ្នាំថ្មីឆ្នាំ២០០៣ សូមប្រកបបានតែសេចក្ដីសុខចំរើនគ្រប់ប្រការ និងសំរេចបានជ័យជំនះគ្រប់ភារកិច្ច ។

ការបែកគ្នាមួយរយៈនេះ បានធ្វើអោយយើងខ្ញុំមានការសោកស្ដាយជាទីបំផុត ចំពោះការទន្ទឹងរង់ចាំរបស់ប្រិយមិត្តយើង ។ មិត្តយើងខ្លះងឿងឆ្ងល់ និងខ្លះទៀតហាក់ដូចជាអស់សង្ឃឹមថានឹងបានជួបគ្នាជាថ្មីឡើងវិញ ។

យើងបានដឹងហើយថា "ទស្សនាវដ្ដីគ្រូបង្រៀន" ដែលបានប្រសូតឡើងតាំងពីលេខ ១ រហូតមកនោះ គឺអាស្រ័យដោយការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការនាយកក៏ពិតមែន តែក៏អាស្រ័យដោយជំនួយឧបត្ថម្ភទាំងស្រុងពីប៉ាសិច (PASEC) ផងដែរ ។ ជាចៃដន្យណាស់ ពេលដែលអស់ជំនួយប៉ាសិច គឺចំពេលដែលលោកប្រធានគណៈកម្មាធិការមានសុខភាពថមថយដោយជរាពាធ និងរោគា ។ ការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការ ទោះជាមានការជួយជ្រោមជ្រែងពីគ្រប់ខេត្ត-ក្រុងក៏ដោយ ក៏នៅបានទទួលផលយឺត និងតិចតួចណាស់ គឺយើងនៅអាចបោះពុម្ពផ្សាយបានក្នុងកំរិតចំនួនមួយកុំអោយតែដាច់នូវលេខ១១...លេខ១២...និងលេខ១៣...កាន់តែរយាលទៅៗ....ឆ្ងាយទៅៗ..... ។

ឆ្នាំថ្មី! ការប្រឹងប្រែងថ្មី! ទស្សនាវដ្ដីលេខថ្មី! លេខ១៤!

យើងបានប្ដេជ្ញា ពុះពាររាល់ការលំបាកគ្រប់បែបយ៉ាង ធ្វើយ៉ាងណាអោយចលនាជីពចរទស្សនាវដ្ដីបានដើរស្រួលជាប្រក្រតីឡើងវិញ ដើម្បីបំរើឧត្ដមគតិ និងប្រពៃណីរបស់ខ្លួនក្នុងការលើកកំពស់សាមគ្គីភាព ការយោគយល់គ្នារវាងគ្រូបង្រៀននិងគ្រូបង្រៀនផងគ្នា ការផ្ដល់ចំណេះដឹង បទពិសោធន៍ទៅវិញទៅមក ការលើកកំពស់មុខវិជ្ជាជីវៈ និងគុណភាពអប់រំ ។

សូមជំរាបជាពតិមានថា ពីលេខ ១៤ ដល់ លេខ ១៩ យើងអាចបោះពុម្ពបានប្រហែល៦.០០០ច្បាប់ ក្នុងមួយលេខៗដើម្បីសងបង្គ្រប់៦ត្រីមាសដែលបានអាក់ខាន ។ ហើយចាប់ពីលេខ២០តទៅ ចំនួននេះនឹងធ្លាក់មកប្រហែលត្រឹម៣.០០០ច្បាប់វិញទៅតាមលទ្ធភាពជាក់ស្ដែងរបស់យើង ។

យើងខ្ញុំនៅតែសំណូមពរអំពាវនាវដោយទទូចចំពោះលោកគ្រូ អ្នកគ្រូ សូមមេត្តាជួយទស្សនាវដ្ដីយើងដោយស្មគ្របញ្ចេញមតិយោបល់ទៅលើការអប់រំក្នុងប្រទេស ក្រៅប្រទេស បច្ចុប្បន្នកាល អតីតកាល អនាគតកាល ដើម្បីចែកជូនបុគ្គលិកសិក្សាយើងបានក្រេបជញ្ជក់ចំណេះដឹងថ្មី ពតិមានថ្មី ក្នុងគោលបំណងលើកកំពស់ពុទ្ធិទូទៅ និងវិជ្ជាជីវៈនៃអ្នកអប់រំដែលមានភារកិច្ចផ្ទេរចំណេះដឹងទៅអោយយុវជនជំនាន់ក្រោយ ។ ក្នុងនោះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកខោល ភុន និង លោកប៉ាន់ ត្រា ដែលផ្ដល់អត្ថបទជាទៀងទាត់ដល់ទស្សនាវដ្ដីគ្រូបង្រៀនយើង ។

យើងខ្ញុំរង់ចាំទទួលមតិយោបល់ល្អៗអំពីប្រិយមិត្តអ្នកអានទាំងអស់ដោយសោមនស្សរីករាយ និង សូមអភ័យទោសពីសំណាក់លោកគ្រូ អ្នកគ្រូនូវកង្វះខាត និងកំហុសឆ្គងដែលអាចកើតមានដោយអចេតនានៅលើទំព័រទាំងឡាយនៃទស្សនាវដ្ដី នេះ ។

**គណៈកម្មាធិការនាយក**

# អារម្ភកថា

ប្រជាពលរដ្ឋកម្ពុជាបានទទួលស្គាល់ថា ការអប់រំមូលដ្ឋាន ជាប្រព័ន្ធបណ្តុះបណ្តាលសំរាប់ជនគ្រប់រូបទោះប្រុសក្តីស្រីក្តី ដើម្បីកាត់បន្ថយភាពក្រីក្រ ។

ការអប់រំមូលដ្ឋាននេះ មានរយៈពេលប្រាំបួនឆ្នាំ ( រដ្ឋធម្មនុញ្ញ ជំពូកទី ៦ មាត្រា ៦៨ : "រដ្ឋផ្តល់កិច្ចអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។" ) សំដៅឆ្លើយតបនឹងតំរូវការទាក់ទងនឹងមធ្យោបាយសិក្សា ( អំនាន អក្សរផ្ចង់ សំនួរ វោហារ ផ្ទាល់ខ្លួន ការគិតលេខ ដំណោះស្រាយចំណោទ) ក៏ដូចជាខ្លឹមសារ( -ចំនេះដឹងផ្នែកទ្រឹស្តី -ចំនេះដឹងធ្វើការងារ និងបំនិនជីវិត-ចំនេះដឹងចេះរស់នៅជាមួយគ្នាមានសីលធម៌ល្អជាពលរដ្ឋថ្លៃថ្នូរ និង មានប្រយោជន៍ -ត្រៀមខ្លួនសំរាប់រស់នៅនាសង្គមអនាគត) ដែលមនុស្សជាតិត្រូវការដើម្បី ÷

- ទ្រទ្រង់ជីវិត
- អភិវឌ្ឍរាល់សមត្ថភាពធនធានមនុស្ស
- រស់នៅ និងធ្វើការក្នុងក្តីថ្លៃថ្នូរ
- ចូលរួមអោយបានពេញទំហឹងដល់កិច្ចអភិវឌ្ឍន៍
- ធ្វើអោយគុណភាពនៃអត្ថិភាពរបស់ខ្លួនប្រសើរឡើង
- រួមផ្តល់សេចក្តីសំរេចចិត្តដ៏ភ្លឺស្វាង
- បន្តការសិក្សា ។

ការអប់រំមូលដ្ឋានមិនមែនស្ថិតនៅត្រឹមតែជាគោលដៅរបស់ខ្លួនប៉ុណ្ណោះទេ តែវាជាមូលដ្ឋានមួយសំខាន់សំរាប់ការអប់រំជានិរន្ត និង សំរាប់កិច្ចអភិវឌ្ឍន៍របស់ភាវៈមនុស្សជាតិ ។

ទស្សនវិស័យទូលាយរបស់ការអប់រំមូលដ្ឋាន ត្រូវបានគួបផ្សំគ្នាជាអង្គឯកភាពមួយរួមមាន ÷

- កុមារទាំងអស់ ព្រមទាំងជំទង់ និងមនុស្សចាស់ផងដែរ
- ប្រព័ន្ធសំខាន់ចាំបាច់នៃការបណ្តុះបណ្តាលចំពោះកុមារ ក្រៅពីគ្រួសារនោះ គឺសាលាបឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ
- ការហ្វឹកហាត់ដែលត្រូវផ្សារភ្ជាប់នឹងបរិការណ៍ និងសង្គម ត្រូវធានាដល់អ្នកហ្វឹកហាត់ទាំងអស់នូវស្បៀងអាហារ ការថែទាំសុខភាព ហើយជាទូទៅការគាំទ្រកំលាំងកាយ និង សញ្ចេតនាដែលពួកគេត្រូវការដើម្បីមានលទ្ធភាពចូលប្រលូកដោយសកម្មក្នុងការអប់រំ ។

**គណៈកម្មាធិការនាយក**



# ជីវប្រវត្តិព្រឹទ្ធាចារ្យ យ៉ង់ ឆឹ

លោក **យ៉ង់ ឆឹ** កើតនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩២៤ នៅភូមិក្រូចសើច ឃុំកោះអណ្ដែត ស្រុក ស្រីសន្ធរ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ **យ៉ង់ ឡូរាត់** ម្ដាយឈ្មោះ **ស៊ឹម ម៉ៅ** ជាកសិករ ។ ភរិយាឈ្មោះ **ឈិត ស៊ុយេន** កើតឆ្នាំ ១៩៣៤ នៅខេត្តកំពង់ចាម បានធ្វើមរណកាលក្នុងរបបប៉ុលពតឆ្នាំ ១៩៧៦ ។ លោកមានបុត្រចំនួន ៦ នាក់ : ប្រុស ២នាក់ និងស្រី ៤នាក់ ។

ក្នុងមួយជីវិតលោកព្រឹទ្ធាចារ្យ **យ៉ង់ ឆឹ** បានលះបង់មិនខ្លាចនឿយហត់ដើម្បីបុព្វហេតុអប់រំ ជាពិសេសបុព្វហេតុសមាគមបុគ្គលិកសិក្សាខ្មែរ ជាក់ស្ដែង :

១-**ការសិក្សា** :

១៩៣៤-១៩៤៤ : សិស្សបឋមសិក្សានៅខេត្តកំពង់ចាម មធ្យមសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ

១៩៤៤-១៩៤៥ : គរុសិស្សសាលាគរុកោសល្យភ្នំពេញ

២-**មុខងារ** :

១៩៤៥-១៩៧៥ : -គ្រូបង្រៀនបឋមសិក្សានៅខេត្តព្រៃវែង

-នាយកសាលារៀននៅខេត្តព្រៃវែង

-នាយកតំបន់អធិការកិច្ចសាលាបឋមសិក្សានៅខេត្តកំពង់ស្ពឺ

-អធិការបឋមសិក្សានៅខេត្តកំពង់ស្ពឺ

-អភិបាលសាកលវិទ្យាល័យភូមិន្ទកំពង់ចាម

១៩៨០-១៩៩០ : ប្រធាននាយកដ្ឋានឧត្តមសិក្សា និងសិក្សាឯកទេសនៅក្រសួងអប់រំ យុវជន និង កីឡា ។

១៩៩១ : ចូលនិវត្តន៍

១៩៩៥-១៩៩៨ : ទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឋានៈស្មើនឹង រដ្ឋលេខាធិការ ។

៣-**<u>បទពិសោធន៍</u>** :

- អធិការថ្នាក់រៀន និងសាលាបឋមសិក្សា
- គ្រប់គ្រងរដ្ឋបាលសាលារៀន និងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

៤-**<u>ទស្សនកិច្ចសិក្សា និងកម្មសិក្សា</u>** :

១៩៥៩ : ទស្សនកិច្ចសិក្សានៅប្រទេសឥណ្ឌាក្នុងក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍសហគមន៍

១៩៦៣-១៩៦៤ : កម្មសិក្សាអធិការកិច្ចសាលាបឋមសិក្សានៅ ម៉ុងប៉េល្លីយេ ( ប្រទេសបារាំង ) ។

៥-**<u>ការចូលរួមសន្និសីទអន្តរជាតិ</u>** :

១៩៨០-១៩៨៨ : សមាជិកគណៈប្រតិភូក្រសួងអប់រំ ចូលរួមសន្និសីទអន្តរជាតិ ស្តីពីការអប់រំ មូលដ្ឋាន និងឧត្តមសិក្សា និងសិក្សាឯកទេស :

- សាធារណរដ្ឋសង្គមនិយមវៀតណាម ៣លើក
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ១លើក
- សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ៣លើក

១៩៨៦ : ការប្រជុំអន្តរជាតិស្តីពីផែនការកម្មអប់រំនៅប៊ែរឡាំង ( សាធារណរដ្ឋប្រជាធិបតេយ្យ អាល្លឺម៉ង់ ) ។

៦-**<u>សកម្មភាពផ្សេងៗ</u>** :

១៩៩៤-២០០២ : ប្រធានគណៈកម្មាធិការកណ្តាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ

១៩៩៥ : - និពន្ធ និងផ្សព្វផ្សាយទស្សនាវដ្តីគ្រូបង្រៀនចំនួន ១៣លេខ

- អ្នកពិគ្រោះការនៃការបណ្តុះបណ្តាលអធិការបឋមសិក្សានៅមហាវិទ្យាល័យ គរុកោសល្យ ។

- និពន្ធសៀវភៅប្រវត្តិខ្ញុំផ្ទាល់
- និពន្ធសៀវភៅអត្តសញ្ញាណកម្ពុជា
- និពន្ធសៀវភៅសីលធម៌ទ្រទ្រង់មនុស្សជាតិ
- និពន្ធប្រវត្តិអប់រំនៅកម្ពុជា
- គំនិតផ្តួចផ្តើមមហាសាមគ្គីក្នុងគ្រួសារគ្រូបង្រៀន ក្នុងការស្ថាបនាផ្ទះគ្រូ បង្រៀន ។

**៧-<u>ការទទួលគ្រឿងឥស្សរិយយស</u> :**

- មេដាយពលកម្ម
- មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនា

លោកព្រឹទ្ធាចារ្យ **យ៉ង់ ឌី** បានធ្វើមរណកាល ក្នុងតួនាទីជាធរមាន ប្រធានគណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ នៅថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ស្រាពណ៍ ឆ្នាំ មមី ចត្វាស័ក ព.ស ២៥៤៦ ត្រូវនឹង ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ វេលាម៉ោង ៨យប់ ក្នុងជន្មាយុ ៨១ឆ្នាំ ដោយជរាពាធ ។

> **"កាលរស់នៅ ត្រូវធ្វើការ ណាមួយ**
> **ទុកជំនួយ ជួយចំណែក ចែកដល់ជាតិ**
> **កុំកើតឡើង ស្លាប់ទៅវិញ ឥតស្អាត**
> **ទុកតែធាតុ មួយកញ្ចប់ ប៉ុណ្ណោះឡើយ ៗ"**
>
> ឱម ណាត្រី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមអប្បកិច្ចគ្រូខ្មែរ

Association Mutualiste du Corps Enseignant Khmer/
Ligue Cambodgienne de l'Enseignement.

លេខ : ៣៩ គក

## ការកំណត់បែងចែកភារកិច្ច

**គណៈកម្មាធិការនាយក ស.ប.ស.ខ**

**អាណត្តិទី ៤ ឆ្នាំ២០០៣_២០០៤**

- យោងលក្ខន្តិកៈសមាគមអប្បកិច្ចសិក្សាខ្មែរ ជំពូកទី៣ ប្រការ១២ និងប្រការ២៧
- យោងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយក ស.ប.ស.ខ. ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២
- យោងសេចក្តីសំរេចរបស់អង្គប្រជុំគណៈកម្មាធិការនាយកធ្វើកាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០២

**គណៈកម្មាធិការនាយក ស.ប.ស.ខ**

បានសំរេចបែងចែកភារកិច្ចជូនសមាជិកទាំង ១៥រូប ដូចតទៅ :

| | | | |
|---|---|---|---|
| ១- ប្រធាន | : លោក រស់ ស៊ីវ | ២- អនុប្រធាន | : លោកជំទាវ ឡុង សើ |
| ៣- អគ្គលេខាធិការ | : លោក ស៊ុន ចាន់ថន | ៤- អគ្គលេខាធិការរង | : លោក ស្វាយ ធិត្យ |
| ៥- អគ្គហិរញ្ញិក | : លោក ទឹម ឃឹម | ៦- អគ្គហិរញ្ញិករង | : លោក អៅ ហឿន |
| ៧- បណ្ណារក្ស | : លោក ជំទាវ ទឹម ណារ៉ុម និង | | : លោកស្រី ចន សុភី |
| ៨- ស្នងការ | : លោក ស៊ុន ស៊ីម | | : លោក ថេង ឌុវ៉ាល់ |
| | : លោកស្រី ឃួន សុមិជា | | : លោក ទឹម សារិន ✓ |

៩- គណៈកម្មការត្រួតពិនិត្យ : លោក សុខ សារុន ប្រធាន
: លោក ជុំ ស៊ុន សមាជិក
: លោកស្រី គុយ ផល្លា សមាជិកា

ភ្នំពេញថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០២

គណៈកម្មាធិការនាយក ស.ប.ស.ខ

រស់ ស៊ីវ

កន្លែងចម្លង :

- ក្រសួងមហាផ្ទៃ
- [illegible]
- [illegible]
- [illegible]
- គណៈកម្មាធិការ ស.ប.ស.ខ គ្រប់ខេត្ត-ក្រុង
- [illegible]

# សេចក្តីស្រង់ព្រះរាជក្រឹត្យ

នស/រកត/១២០១/៤៥០

## ព្រះរាជក្រឹត្យ

## ស្តីពី

## បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស

## របស់មន្ត្រីរាជការស៊ីវិល

* * *

**យើង**

**ព្រះករុណាសម្តេច ព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ......................................................................
- ......................................................................

**ត្រាស់បង្គាប់**

**មាត្រា ១**

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស គឺជាកំរៃជីវភាពប្រចាំខែដែលរដ្ឋត្រូវផ្តល់ជូនមន្ត្រីរាជការស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលក្នុងការបំពេញការងារ ។ បៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរួមមាន :

- បៀវត្សមូលដ្ឋាន

- ប្រាក់បំណាច់មុខងារ
- ប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ

## ជំពូកទី ១

## បៀវត្សមូលដ្ឋាន

**មាត្រា ២**

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែដែលត្រូវផ្ដល់ជូនមន្ត្រីរាជការសំរាប់ជីវភាពរស់នៅក្នុងនោះមាន : គ្រឿង ឧបភោគបរិភោគ ការស្នាក់នៅ សំលៀកបំពាក់ ការព្យាបាលជំងឺ ។ល។

**មាត្រា ៣**

បៀវត្សមូលដ្ឋាននៃមន្ត្រីរាជការ ត្រូវបែងចែកទៅតាមប្រភេទ ឋានន្តរស័ក្តិ និងថ្នាក់ដែលត្រូវបានកំណត់ទៅតាមកំរិតនៃសន្ទស្សន៍ដូចខាងក្រោម :

| ប្រ. ភ | ឋានន្តរស័ក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| ក | ក១ | | | | | | | | | ៤៣៦ | ៤៥៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| | ក២ | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៩ | ៤៣៧ | ៤៥៤ | ៤៦៧ | ៤៧៨ | ៤៨៧ |
| | ក៣ | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៩ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| ខ | ខ១ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| | ខ២ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| | ខ៣ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| គ | គ១ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| | គ២ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| | គ៣ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| ឃ | ឃ១ | | | | | | | | | ១៤១ | ១៤៩ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| | ឃ២ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |
| | ឃ៣ | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

**មាត្រា ៤**

តំលៃឯកតានៃសន្ទស្សន៍សំរាប់អនុវត្តក្នុងតារាងបៀវត្សមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈមាន ចំនួន ៣០០ រៀល ។

ការកែប្រែតំលៃឯកតានៃសន្ទស្សន៍នេះ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

# ជំពូកទី ២
# ប្រាក់បំណាច់មុខងារ

**មាត្រា ១៣**

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើបៀវត្សមូលដ្ឋានប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការនៅ ក្នុងប្រភេទ **ក, ខ,** និង **គ** ហើយដែលកំពុងបំពេញការងារក្នុងក្រសួងស្ថាប័ន ។

**មាត្រា ១៤**

ប្រាក់បំណាច់មុខងារ ត្រូវបានបែងចែកជា ០៥ កាំរិត ទៅតាមរយៈពេល និងបទពិសោធន៍ការងារក្នុងមុខតំណែងនីមួយៗ ដូចខាងក្រោម :

- -កាំរិតទី ៥ សំរាប់បទពិសោធន៍រយៈពេលក្រោម ០៣ឆ្នាំ
- -កាំរិតទី៤ សំរាប់បទពិសោធន៍រយៈពេលពី ០៣ ទៅ ០៦ឆ្នាំ
- -កាំរិតទី៣ សំរាប់បទពិសោធន៍រយៈពេលពី ០៦ ទៅ ១០ឆ្នាំ
- -កាំរិតទី២ សំរាប់បទពិសោធន៍រយៈពេលពី ១០ ទៅ ១៦ឆ្នាំ
- -កាំរិតទី១ សំរាប់បទពិសោធន៍រយៈពេលលើសពី ១៦ឆ្នាំ

**មាត្រា ១៥**

ការផ្លាស់ប្តូរកាំរិត និងការផ្តល់ប្រាក់បំណាច់មុខងារ មិនអាចអនុវត្តទៅតាមឆ្នាំកំណត់ ដូចបានចែងនៅ ក្នុងមាត្រា ១៤ ជាស្វ័យប្រវត្តិបានទេ ក៏ប៉ុន្តែត្រូវធ្វើឡើងដោយមានការវាយតំលៃពីប្រធានស្ថាប័ន ។

**មាត្រា ១៦**

មន្ត្រីរាជការដែលមានមុខតំណែងដូចខាងក្រោម ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងភ្ជាប់ជាមួយនេះ :

| ល.រ | មុខងារ | កាំរិត ទី៥ | កាំរិត ទី៤ | កាំរិត ទី៣ | កាំរិត ទី២ | កាំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | អគ្គលេខាធិការ រាជរដ្ឋាភិបាល | ៧៨០ ០០០៛ | ៨២៧ ០០០៛ | ៨៧៧ ០០០៛ | ៩៣០ ០០០៛ | ៩៨៦ ០០០៛ |
| ២ | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | ៧៦៥ ០០០៛ | ៨១១ ០០០៛ | ៨៦០ ០០០៛ | ៩១២ ០០០៛ | ៩៦៧ ០០០៛ |
| ៣ | អគ្គលេខាធិការ | ៧៥០ ០០០៛ | ៧៩៥ ០០០៛ | ៨៤៣ ០០០៛ | ៨៩៤ ០០០៛ | ៩៤៨ ០០០៛ |
| ៤ | អគ្គនាយក | ៧៣៥ ០០០៛ | ៧៧៩ ០០០៛ | ៨២៦ ០០០៛ | ៨៧៦ ០០០៛ | ៩២៩ ០០០៛ |
| ៥ | អគ្គាធិការ | ៧២០ ០០០៛ | ៧៦៣ ០០០៛ | ៨០៩ ០០០៛ | ៨៥៨ ០០០៛ | ៩១០ ០០០៛ |
| ៦ | អភិបាល ខេត្ត-ក្រុង | ៧០៥ ០០០៛ | ៧៤៧ ០០០៛ | ៧៩២ ០០០៛ | ៨៤០ ០០០៛ | ៨៩១ ០០០៛ |
| ៧ | សកលវិទ្យាធិការ | ៦៩០ ០០០៛ | ៧៣២ ០០០៛ | ៧៧៦ ០០០៛ | ៨២៣ ០០០៛ | ៨៧៣ ០០០៛ |
| ៨ | សាស្ត្រាចារ្យមហាបរិញ្ញា | ៦៧៥ ០០០៛ | ៧១៦ ០០០៛ | ៧៥៩ ០០០៛ | ៨០៥ ០០០៛ | ៨៥៣ ០០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | អគ្គលេខាធិការរង | ៦៦០ ០០០៛ | ៧០០ ០០០៛ | ៧៤២ ០០០៛ | ៧៨៧ ០០០៛ | ៨៣៤ ០០០៛ |
| ១០ | អគ្គនាយករង | ៦៤៥ ០០០៛ | ៦៨៤ ០០០៛ | ៧២៥ ០០០៛ | ៧៦៩ ០០០៛ | ៨១៥ ០០០៛ |
| ១១ | អគ្គាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |
| ១២ | សកលវិទ្យាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |

## មាត្រា១៧

ប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរដ្ឋបាលទូទៅ ត្រូវផ្ដល់ជូនចំពោះមន្ត្រីរាជការដែលកំពុងបំពេញមុខងារក្នុងមុខតំណែងដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន ដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ប្រធាន នាយកដ្ឋាន | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ២ | អធិការ | ៥៧ ៥០០៛ | ៦២ ១០០៛ | ៦៧ ១០០៛ | ៧២ ៥០០៛ | ៧៨ ៣០០៛ |
| ៣ | អនុប្រធាន នាយកដ្ឋាន | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៤ | អធិការរង | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៤០០៛ |
| ៥ | ប្រធានមន្ទីរខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៦ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៧ | ប្រធានការិយាល័យថ្នាក់កណ្ដាល | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៨ | អនុប្រធានមន្ទីរខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អនុប្រធានការិយាល័យថ្នាក់កណ្ដាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ១០ | ប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ | ៤៤ ១០០៛ | ៤៧ ៦០០៛ |
| ១២ | ប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៤ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៣ | មន្ត្រីក្រមការ | ៣០ ០០០៛ | ៣២ ៤០០៛ | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ |
| ១៤ | អនុប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៥ | លេខាធិការឈើមខ្សៃ | ២២ ៥០០៛ | ២៤ ៣០០៛ | ២៦ ៣០០៛ | ២៨ ៤០០៛ | ៣០ ៧០០៛ |
| ១៦ | លេខាធិការ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |

....................................................................................................

....................................................................................................

## មាត្រា ១៩ : ប្រាក់បំណាច់មុខងារប្រចាំខែក្នុងវិស័យអប់រំ មានដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០ ០០០៛ | ៨៤ ០០០៛ | ៨៨ ២០០៛ | ៩២ ៦០០៛ | ៩៧ ២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៣ | សាស្ត្រាចារ្យ ឧត្តមសិក្សា | ៧៧ ០០០៛ | ៨០ ៩០០៛ | ៨៥ ០០០៛ | ៨៩ ៣០០៛ | ៩៣ ៨០០៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | នាយក វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៥ | នាយក វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៦ | នាយក វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៧ | គ្រូបង្រៀន ឧត្តមសិក្សា | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ | ៨៧ ០០០៛ | ៩១ ៤០០៛ |
| ៨ | នាយករង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ៩ | នាយករង វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១០ | នាយករង វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១១ | អធិការ មធ្យមសិក្សា | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១២ | នាយក វិទ្យាល័យ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៣ | នាយក មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៤ | នាយក សាលាគរុកោសល្យខេត្ត-ក្រុង | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៥ | នាយក មជ្ឈមណ្ឌលបច្ចេកទេស និងវិជ្ជាជីវៈ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៦ | នាយក សាលាមធ្យមសិក្សាបច្ចេកទេសឫស្សីកែវ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៧ | នាយក សាលាមធ្យមសិក្សាអប់រំកាយ និងកីឡា | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៨ | នាយក សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៩ | នាយក រងវិទ្យាល័យ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២០ | នាយករង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២១ | នាយករង សាលាគរុកោសល្យខេត្ត-ក្រុង | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២២ | នាយករង មជ្ឈមណ្ឌលបច្ចេកទេស និងវិជ្ជាជីវៈ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៣ | នាយករង សាលាមធ្យមសិក្សាបច្ចេកទេសឫស្សីកែវ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៤ | នាយករង សាលាមធ្យមសិក្សាអប់រំកាយ និងកីឡា | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៥ | នាយករងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៦ | គ្រូបង្រៀន មធ្យមសិក្សា ទុតិយភូមិ | ៧១ ០០០៛ | ៧៤ ៦០០៛ | ៧៨ ៣០០៛ | ៨២ ២០០៛ | ៨៦ ៣០០៛ |
| ២៧ | អធិការ បឋមសិក្សា | ៦៩ ០០០៛ | ៧២ ៥០០៛ | ៧៦ ១០០៛ | ៧៩ ៩០០៛ | ៨៣ ៩០០៛ |
| ២៨ | នាយក អនុវិទ្យាល័យ | ៦៨ ០០០៛ | ៧១ ៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ២៩ | នាយក មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៨ ០០០៛ | ៧១ ៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ៣០ | នាយករង អនុវិទ្យាល័យ | ៦៧ ០០០៛ | ៧០ ៤០០៛ | ៧៣ ៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣១ | នាយករង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៧ ០០០៛ | ៧០ ៤០០៛ | ៧៣ ៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣២ | គ្រូបង្រៀន មធ្យមសិក្សា បឋមភូមិ | ៦៦ ០០០៛ | ៦៩ ៣០០៛ | ៧២ ៨០០៛ | ៧៦ ៥០០៛ | ៨០ ៣០០៛ |
| ៣៣ | នាយក សាលាបឋមសិក្សា | ៦៤ ០០០៛ | ៦៧ ២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៤ | នាយក សាលាមត្តេយ្យ | ៦៤ ០០០៛ | ៦៧ ២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៥ | នាយករង សាលាបឋមសិក្សា | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៦ | នាយករង សាលាមត្តេយ្យ | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៧ | គ្រូបង្រៀន បឋមសិក្សា មត្តេយ្យសិក្សា | ៦២ ០០០៛ | ៦៥ ១០០៛ | ៦៨ ៤០០៛ | ៧១ ៨០០៛ | ៧៥ ៤០០៛ |
| ៣៨ | គ្រូបង្រៀន កម្រិតបឋម | ៦០ ០០០៛ | ៦០ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ |

**មាត្រា ២០**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ពរល-០១-១២-០០៨៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**ហត្ថលេខា**

**សុខ អាន**

លេខ: ២៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា**

**ឈាវ តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលការអនុវត្ត របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- .......................................................
- .......................................................

### សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១**

អនុក្រឹត្យនេះ មានគោលបំណងកែសំរួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការដែលបានចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ តាមប្រព័ន្ធបៀវត្សចាស់ និងការអនុវត្តប្រាក់សោធនចំពោះមន្ត្រីរាជការចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈតាមប្រព័ន្ធបៀវត្សថ្មី ដោយអនុលោមតាមខ្លឹមសារព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យ អប់រំ ។

### ជំពូកទី ២

### ការអនុវត្តប្រាក់សោធនក្នុងប្រព័ន្ធបៀវត្សចាស់

មាត្រា ២

និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនគិតតាមប្រព័ន្ធបៀវត្សចាស់មកដល់ ត្រឹមថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០២ ត្រូវបានកែសំរួលប្រាក់សោធនប្រចាំខែអោយដូចប្រាក់សោធននៃមន្រ្តីរាជការចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈតាមប្រព័ន្ធបៀវត្សថ្មី មិនត្រូវទាបជាងប្រាក់សោធនគិតតាមប្រព័ន្ធ បៀវត្សចាស់ ដែលសាមីជនកំពុងទទួលឡើយ ។ ក្នុងករណីទាបជាង ត្រូវផ្តល់ប្រាក់បង្រ្គប់ជូនសាមីជននោះ ។

## ជំពូកទី ៣

## ការអនុវត្តប្រាក់សោធនតាមប្រព័ន្ធបៀវត្សថ្មី

មាត្រា ៣

ប្រាក់សោធនប្រចាំខែរបស់មន្រ្តីរាជការស៊ីវិលដែលចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ ការផ្តល់ប្រាក់សោធន ត្រូវគណនាតាមបៀវត្សមូលដ្ឋានប្រចាំខែចុងក្រោយនៃមន្រ្តីរាជការស៊ីវិល ទាំងនោះ ។

ប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់ៗត្រូវបានគិតបន្ថែមប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ ។ ប្រាក់វិភាជន៍សំរាប់កូនក្នុងបន្ទុកត្រូវផ្តល់ជូនរហូតដល់អាយុ ១៥ឆ្នាំ ។ ការផ្តល់ជូននេះ អាចបន្ត រហូតដល់អាយុ ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា ។

ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត មិនត្រូវបានរាប់បញ្ចូលឡើយ ។

របៀបគណនាប្រាក់សោធនត្រូវរក្សាទុកដូចមានចែងក្នុងអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះ មន្រ្តីរាជការស៊ីវិល ។

........................................................................................................................................

........................................................................................................................................

មាត្រា ៦

រដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្រ្តីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្រ្តីរដ្ឋលេខា- ធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

**នាយករដ្ឋមន្រ្តី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្រ្តី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ




# ផលវិបាកនៃកំណើនប្រជាជនឆាប់រហ័ស

ក្នុងប្រទេសមួយ ប្រសិនបើប្រជាជនកើនឡើងឆាប់រហ័សនោះ វានឹងប៉ះពាល់យ៉ាងខ្លាំងដល់ប្រទេសជាតិនោះ ។

## <u>ផលប៉ះពាល់សេដ្ឋកិច្ច-សង្គមកិច្ច</u>

កំណើនប្រជាករទាមទារផ្ទៃដីកាន់តែធំ និងធនធានទឹក ខ្យល់កាន់តែច្រើន។ ល្អិកណាមានកំណើនឆាប់ រហ័ស ល្អិកនោះការផ្គត់ផ្គង់តម្រូវការរឹតតែដោះស្រាយមិនទាន់ ហើយជះឥទ្ធិពលដល់ជីវភាពប្រជាជន ធ្វើអោយ ប្រជាជនធ្លាក់ក្នុងភាពក្រីក្រ ។ ភាពក្រីក្រនេះ ធ្វើអោយមនុស្សជឿអ្វីៗគ្រប់យ៉ាងសំរាប់ជីវិត។ គេបំផ្លាញបរិស្ថាន រឺ បំផ្លាញដី បំរុងបរិស្ថាន ។ បច្ចុប្បន្ននេះ ប្រជាជនលើសកលលោករាប់រយលាននាក់កំពុងប្រឈមមុខនឹងភាពអត់ឃ្លាន ដោយសារតែកំណើនឆាប់រហ័សនេះ។ នេះជាផលប៉ះពាល់ជាក់ស្តែង :

**ផលវិបាកកំណើនប្រជាករឆាប់រហ័សមួយចំនួន :**



## ផលប៉ះពាល់បរិស្ថាន

មនុស្សកាន់តែកើនច្រើន ហើយឆាប់រហ័សទៀតផងនោះ ធ្វើអោយកាកសំនល់កាន់តែច្រើន និងបំពុលបរិយាកាសកាន់តែខ្លាំង។ ទឹកក្រោមដីត្រូវទាញយកមកប្រើប្រាស់ ទឹកទន្លេ ទឹកបឹង ត្រូវបំពុលដោយសារកាកសំនល់ពីរោងចក្រពីទីក្រុង និងកាកសំនល់កសិកម្ម ។

នៅអាព្រិចសាហារ៉ា និងមជ្ឈិមបូព៌ា និងនៅប្រទេសអាស៊ីមួយចំនួន ទឹកអាចប្រើប្រាស់បានតែក្នុងរយៈ ១០ ទៅ ១៥ឆ្នាំទៀត។ ប្រសិនបើ ប្រជាករកើនឆាប់រហ័ស ធនធានធម្មជាតិនោះរឹតតែឆាប់អស់ទៀត ។

ព្រៃត្រូពិច ត្រូវកាប់បំផ្លាញក្នុងមួយឆ្នាំប្រហែល ១៧ លានហិកតា ដើម្បីយកទៅប្រើប្រាស់ជាសំនង់ និងរុករានវាតទីសំរាប់ដាំដុះ ហើយភាគច្រើនដើម្បីធ្វើអុស-ធ្យូង ។

ផ្អែកលើផលវិបាកនៃកំណើននេះ ទីប្រឹក្សាយូណេស្កូមួយរូបបានធ្វើការសន្និដ្ឋានដូចនេះ :

"ប្រជាករពិភពលោកមិនអាចច្រើនជាងបរិមាណធនធានដែលពិភពលោកមានសំរាប់បង្គ្រប់តំរូវការរស់ រឺតំរូវការចិញ្ចឹមជីវិតរបស់មនុស្សលោកទេ ។ កំណើនប្រជាករពិភពលោកកើនឡើងមិនសមស្របនោះ មិនអាចធ្វើអោយបរិស្ថានវិវឌ្ឍរហ័សទាន់តាមតំរូវការបានទេ" ។

(សំរួលអត្ថបទរបស់ UNFPA)

**កែច យ៉ាវ**

### អំពីទុរភិក្ស

កាលបើគេនឹកដល់ពាក្យ "**ទុរភិក្ស**" នោះគេមានរឿងលើកដូចតទៅ :

១- ពិភពលោកកើតទុរភិក្សដោយហេតុតែកង្វះស្បៀង ។

២- ពិភពលោកកើតទុរភិក្សដោយហេតុតែកង្វះដី ។

៣- ផែនដីមានប្រជាជនលើសលុប ។

៤- ដំណោះស្រាយតែមួយគិតនៅលើការផលិតស្បៀងអោយបានច្រើន ។

៥- កម្មសិទ្ធិទ្រង់ទ្រាយធំៗតែម្យ៉ាងអាចដោះស្រាយបញ្ហាទុរភិក្ស ។

៦- ត្រូវបង្កើនផលិតកម្ម រួចទើបធ្វើពលិកម្មលើបរិស្ថាន ។

៧- ប្រទេសនីមួយៗត្រូវតែធ្វើឯកទេសកម្ម ដើម្បីផលិតបានរហ័ស ។

៨- ទុរភិក្សបានស្តែងអោយឃើញច្បាស់រវាងពិភពអ្នកមាន និងពិភពអ្នកក្រ ។

(Les huit mythes de la faim )

# ការស្រុតចុះសីលធម៌របស់សិស្សជំទង់ ក្នុងសង្គមសព្វថ្ងៃ

( អត្ថបទដកស្រង់សង្ខេបពីសមាជលើកទី ៤ នៃការស្រាវជ្រាវសង្គម-វប្បធម៌នៅកម្ពុជាដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី ១២-១៤ ខែវិច្ឆិកា ឆ្នាំ ២០០២ ) ថ្លែងដោយលោកបណ្ឌិត ចាន់ រដ្ឋសុផា នៅសាកលវិទ្យាល័យភូមិន្ទII

សព្វថ្ងៃនេះ យើងសង្កេតឃើញថា សីលធម៌សង្គមស្រុតចុះខ្លាំងគួរឱ្យព្រួយបារម្ភ ជាពិសេសនៅក្នុងជួរសិស្ស ជំទង់ ។ តាមទស្សនៈរបស់លោក **Erikson** លោកស្រី **Marcia** លោក **Watson** លោក **Piaget** និង លោក **Vygotsky** បានអះអាងថា វ័យជំទង់ ជាវ័យដែលជាប់ពាក់ព័ន្ធទៅនឹងទិដ្ឋភាពសង្គមសំខាន់ៗ បី យ៉ាង : ជំរើស វិជ្ជាជីវៈ ជំនឿលើខ្លួនឯង និង បទប្រព្រឹត្តល្មើស ។ ចង់យល់ច្បាស់ពីមូលហេតុនៃការស្រុតចុះសីលធម៌របស់ជំទង់ យើងគប្បីស្វែងយល់ស៊ីជំរៅទៅលើធាតុផ្សេងនៃបុគ្គលិកលក្ខណៈរបស់ជំទង់ជាមុនសិន ។ បុគ្គលិកលក្ខណៈរួមមាន : ទំនោរតំរូវការថ្មី ចំណង់ចំណូលចិត្តថ្មី លោកទស្សនៈ សម្បទាថ្មី អាកប្បកិរិយាថ្មី ឧត្តមគតិថ្មី អត្តចរិតថ្មី ឫកពាថ្មី ចិត្តរំភើបថ្មី សញ្ចេតនាថ្មី ការគិតថ្មី សកម្មភាពថ្មី ចិត្តគំនិតថ្មី បំណងប្រាថ្នាថ្មី ឆន្ទៈ និង មនសិការថ្មី ។ ចំណុចពិសេសបីយ៉ាងដែលគួរឱ្យកត់សំគាល់បានចំពោះជំទង់គឺ បន្លាស់ប្តូរសរីរាង្គកាយ ចិត្តគំនិត និង ឈានចូលវ័យ គ្រប់ការ ។ អាកប្បកិរិយារបស់ជំទង់ខុសគ្នាស្រឡះពីអាកប្បកិរិយារបស់កុមារ ។ សកម្មភាពដ៏សំខាន់របស់ជំទង់ មាន បួន យ៉ាងគឺ ការសិក្សា ពលកម្ម ល្បែងកំសាន្ត និងការសេពគប់មិត្តភក្តិ ។

## មូលហេតុដែលធ្វើឱ្យសីលធម៌របស់ជំទង់សព្វថ្ងៃស្រុតចុះ

មូលហេតុដែលធ្វើឱ្យសីលធម៌សិស្សមធ្យមសិក្សាស្រុតចុះ បណ្តាលមកពីភាពទន់ខ្សោយនៃការអប់រំសីលធម៌ នៅក្នុងមូលដ្ឋានទាំង បី គឺ សង្គម គ្រួសារ និង សាលារៀន ។

ការស្រុតចុះនៃសីលធម៌របស់ជំទង់ ក៏ដូចជាសីលធម៌សាធារណជនក្នុងសង្គម ជាប្រការមួយដែលត្រូវយកចិត្តទុកដាក់លើកកំពស់ និង កែតំរូវឡើងវិញឱ្យបានទាន់ពេលចាប់តាំងពីពេលនេះតទៅ ។ ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងពត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងមហាផ្ទៃ គួរឈរលើគោលការណ៍ឯកភាព គ្នា និង សហការ គ្នាប្រកបដោយប្រសិទ្ធភាពក្នុងការកំចាត់ឱ្យបានជាស្ថាពរ ចំពោះការហូរចូលនៃវប្បធម៌បរទេស ដែលជះឥទ្ធិពលអវិជ្ជមាន មក លើវប្បធម៌ប្រពៃណីខ្មែរដូចជា ខ្សែភាពយន្ត រូបថត ទស្សនាវដ្តី សិចស៊ី ល្បែងស៊ីសង ការចាប់រំលោភកុមារ គ្រឿងញៀន ការចាប់ជំរិត ការបោកប្រាស់ ការលួច ការប្លន់ និង ឃាតកម្ម ដែលចេះតែកើតមានជារៀងរាល់ថ្ងៃនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ រដ្ឋាភិបាលត្រូវតែពិន័យ និង ដាក់ទណ្ឌកម្មដល់ជនល្មើស និង ឧក្រិដ្ឋជនឱ្យរាងចាល ។ ការចាក់ផ្សាយរឿងភាគតាមបណ្តាញទូរទស្សន៍ ការផ្សព្វផ្សាយ ប្រលោម

លោកអាសអាភាសលើទំព័រកាសែត និងទស្សនាវដ្ដី ដែលជះឥទ្ធិពលអវិជ្ជមានមកលើសង្គមខ្មែរ គួរតែហាមឃាត់ទៅតាមកំរិតមួយដ៏សមរម្យ ។ ក្រសួងអប់រំ យុវជន និង កីឡា គួរតែប្រមើលមើលឡើងវិញ ចំពោះខ្លឹមសារអប់រំសីលធម៌នៅគ្រប់កំរិតសិក្សា និងឱ្យតំលៃខ្ពស់ទៅលើការសិក្សាមុខវិជ្ជានេះ ទាំងផ្នែកទ្រឹស្ដីក៏ដូចផ្នែកអនុវត្តជាក់ ស្ដែង ។ ទន្ទឹមនឹងនេះដែរ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្ស គួរឆ្លៀតពេលអប់រំណែនាំកូន ឱ្យចេះស្វែងយល់ ពីអំពើល្អ អំពើអាក្រក់ និងគ្រោះថ្នាក់ដែលកើតឡើងពីទង្វើផ្ទុយនឹងច្បាប់ក្នុងសង្គម ផ្ទុយនឹងប្រពៃណីសីលធម៌ របស់មនុស្សជាតិ ។ អប់រំកុមារឱ្យស្គាល់ប្រពៃណីសីលធម៌ក្នុងសង្គម ចេះយល់ និង មើលឃើញអត្ថប្រយោជន៍ នៃការសិក្សា ការចេះគួរសម ការចេះលើកដៃសំពះ ការចេះថ្វាយបង្គំព្រះ និង ព្រះសង្ឃ និងតាម ដានទង្វើ និង សកម្មភាពកូនឱ្យបានជិតដល់ ។ នាយកសាលារៀន និង ជូរគ្រូបង្រៀនក៏ត្រូវតាមដានទង្វើ និង សកម្មភាពសិស្ស និងអប់រំឱ្យបានទៀងទាត់ផងដែរ និងរកវិធានការឱ្យសិស្សបានរៀនពេញមួយថ្ងៃ ។ ប្រជាពលរដ្ឋ និងអាជ្ញាធរ មូលដ្ឋានដែលរស់នៅក្នុងសង្គមទូទៅ ត្រូវជួយតាមដានសកម្មភាព និងទំនាក់ទំនងរបស់ជំទង់ជាមួយ កូនចៅខ្លួន ឬ កូនចៅអ្នកជិតខាង ហើយឆាប់រាយការណ៍ទៅសមត្ថកិច្ច ទៅអាណាព្យាបាល រឺទៅសាលារៀន សំដៅស្កាត់ឥទ្ធិពល អាក្រក់ និង អប់រំជំទង់អោយបានទាន់ពេលវេលា ។

**" អប់រំសីលធម៌ ជាភារកិច្ចរបស់សង្គមទាំងមូល "**

"ដ្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្គួតធ្វើជា
អំពើអាក្រក់ ឡើតឡក់លីលា ព្រហើនពានពារ
អាចមាសអាចប្រាក់ ៗ
អាចព្រើលអាចប្រាជ្ញ អាចកោងអាចកាច អាចកាប់អាចចាក់
អាចជើងអាចដៃ អាចចាយអាចឆាក់ អាចគ្មានច្រចាក់
អាចម៉ាស៊ីនកាត់ត ៗ"

ច្បាប់ក្រម ង៉ុយ



# ចិត្តវិទ្យា-អប់រំ

## វដ្តជីវិត

មាតាបិតាទាំងឡាយតែងបានកត់សំគាល់ជំហររបស់កូនតាំងពីនៅក្នុងផ្ទៃមកម្ល៉េះ ។ ទារកកំរើកច្រើនត្រូវបានព្យាករណ៍ថាទារកនោះមានសុខភាពល្អ រឺ ទារកនោះមានភេទជាប្រុស ម្យ៉ាងទៀតថាកាលបើកើតមកហើយវានឹងក្លាយជាក្មេងរពឹសច្រើន ។

ការកត់សំគាល់នេះ មានច្រើនបែបច្រើនយ៉ាងប្លែកពីគ្នា ។ ចិត្តវិទូជាច្រើនក៏បានធ្វើការសិក្សា និងវិភាគយ៉ាងលំអិតដោយកំនត់ជាវ័យកាល និងឥរិយាបថរបស់វ័យកាលនីមួយៗ ។

ក្នុងប្រការនេះ លោកអេរិក អេរិកសុន ចិត្តវិទូអាល្លឺម៉ង់បានលើកជាទ្រឹស្តីមួយ" ទ្រឹស្តីវដ្តជីវិត" ដែលក្នុង វដ្តនីមួយៗមានឥរិយាបថមួយពិសេស ។ ប្រសិនបើយើងមិនចេះសំរបសំរួលអោយសក្តិសមនឹងឥរិយាបថនោះរឺ ធ្វើផ្ទុយនោះ វានឹងក្លាយទៅជាប្រការដទៃដែលអោយខកចិត្ត ខកថ្លើមរបស់គេ ។ ឧទាហរណ៍ ក្នុងពេលដែលកុមារ ពុំទាន់មានពំនឹងផ្ទាល់ខ្លួនបានកុមារទុកចិត្តទាំងស្រុងទៅលើអ្នកដទៃពិសេសលើមាតាបិតា ។ ក្នុងខណៈនេះ យើងមិនត្រូវធ្វើអ្វីដែលបណ្តាលអោយកុមារបាត់ជំនឿអស់សង្ឃឹមឡើយ ហើយលោក អេរិកសុន បានលើកយក ឥរិយាបថ ៧ សំរាប់អោយយើងថែបំប៉ន ដើម្បីជៀសវាងអ្វីៗដែលផ្ទុយនឹងឥរិយាបថនោះជាក់ស្តែង :

- **ទារក** : ការទុកចិត្តផ្ទុយនឹងការមិនទុកចិត្ត

ក្នុងឆ្នាំដំបូងនៃជីវិតកុមារ ពឹងផ្អែកទាំងស្រុងទៅលើមាតាបិតា ។ បន្ទាប់មក កុមារជឿទុកចិត្តទៅតាមតំរូវការរបស់គេដូចជា សេចក្តីស្រលាញ់ ការថ្នាក់ថ្នម ការថែរក្សា ។ ប្រសិនបើគ្មានការថែរក្សា និងការស្រលាញ់ទារកនឹងមានពន្លកឥរិយាបថមិនទុកចិត្តអ្នកដទៃក៏ដូចជាចំពោះជីវិតរបស់ខ្លួន ។

- **កុមារ** : ស្វ័យភាពផ្ទុយនឹងសេចក្តីខ្មាស់ និងការសង្ស័យ

ចន្លោះអាយុ ២-៣ឆ្នាំ កុមាររៀនដើរ រៀននិយាយ ។ កុមារ ចាប់ផ្តើមរៀនទៅបន្ទោរបង់ដោយផ្ទាល់ ។ នៅតំណាក់ការនេះ កុមារត្រូវតែអភិវឌ្ឍស្មារតីឯករាជ្យ និងធ្វើជាម្ចាស់លើបរិស្ថាន ជុំវិញ និងលើខ្លួនឯង ។ មាតាបិតាត្រូវលើកទឹកចិត្តឯករាជ្យភាព និងធ្វើការបណ្តុះបណ្តាលការធ្វើអនាម័យជាវិជ្ជមានជាជាងការស្តីបន្ទោស ។

- **កុមារភាពបឋម** : គំនិតផ្តួចផ្តើមផ្ទុយនឹងពិរុទ្ធភាព

អាយុពី ៤-៥ ឆ្នាំ ជាវ័យកំនើនឯករាជ្យភាព ។ គ្រួសារត្រូវតែអនុញ្ញាតអោយកុមារអភិវឌ្ឍគំនិតផ្តួចផ្តើមស្របពេលជាមួយការអប់រំថាមពលរបស់កុមារ ។ កុមារត្រូវតែបានធ្វើអោយមានអារម្មណ៍មានការទុក្ខព្រួយអំពីបំនងប្រាថ្នារបស់ខ្លួនដើម្បីស្វែងយល់ពិភពលោក ។

- **វ័យសិក្សា** : ឧត្តមភាពផ្ទុយនឹងហីនភាព

ចន្លោះអាយុ ៦-១១ ឆ្នាំ កុមារចាប់ផ្តើមយល់ថា សកម្មភាពរបស់គេមានតំលៃដែលគេអាចច្នៃប្រឌិត ។ គ្រួសារត្រូវតែលើកទឹកចិត្តស្មារតីបំពេញកិច្ចការរបស់កុមារ ។ ការខកខានមិនបានបំពេញទឹកចិត្តអាចបណ្តាលអោយកុមារមានអារម្មណ៍ថាខ្លួនអន់ជាងអ្នកដទៃ ។

- **វ័យជំទង់** : អត្តសញ្ញាណផ្ទុយនឹងការសាយភាយតួនាទី

ក្នុងរយៈពេលពេញវ័យចន្លោះ ១២-១៨ ឆ្នាំ ជារយៈពេលរំជើបរំជួលចិត្តដែលយុវជនអាចសាកល្បងតួនាទី ជាច្រើន ។ វាជារយៈពេលអន្តរកាលជោគជ័យ ។ ពួកគេត្រូវតែអភិវឌ្ឍគោលដៅទស្សនវិជ្ជានៃជីវិតស្មារតីបុគ្គល ។ គ្រួសារត្រូវតែទ្រទ្រង់ការរំជើបរំជួលចិត្ត ។ ប្រសិនបើ វ័យជំទង់ខកខានមិនបានស្គាល់នាអត្តសញ្ញាណជាក់ស្តែងរបស់ខ្លួន វាដូចជាគ្មានគោលបំនងច្បាស់លាស់ ។

- **មនុស្សពេញវ័យដំបូង** : ភាពស្និទ្ធស្នាលផ្ទុយនឹងភាពឯកោ

មានរយៈពេលមួយដែលមនុស្សពេញវ័យចាកចេញពីផ្ទះសំបែង និងបង្កើតចំនងស្និទ្ធស្នាលជាមួយអ្នកដទៃតាមរយៈអាពាហ៍ពិពាហ៍ ការរួមរស់ជាមួយគ្នា ។ ប្រសិនគ្មានចំនងភាពស្និទ្ធស្នាលជាមួយអ្នកដទៃ មនុស្សពេញវ័យដំបូងអាចស្ថិតក្នុងភាពឯកោ ។

- **មនុស្សពេញលេញ** : ការបង្កើតផ្ទុយនឹងការទទួលយក

ឥឡូវនេះ បុគ្គលបង្កើតគ្រួសាររបស់ខ្លួន មានកូន និងស្វែងរកការពេញចិត្តរបស់ខ្លួន រឺ គ្រួសាររបស់ខ្លួន មាន កូន និងស្វែងរកការពេញចិត្តក្នុងកិច្ចទំនាក់ទំនងក្នុងគ្រួសារ ។ ពេលនេះ ជារយៈពេលនៃការបង្កើតថ្មី ។ ការងារជាសកម្មភាពច្នៃប្រឌិតសំខាន់ប្រហែលជាសំខាន់ដូចគ្រួសារ រឺ ជំណោះដូរចំពោះគ្រួសារ ។ ការខកខានផលិតអ្វីមិនបានអាចនាំទៅដល់ការប្រមូលផ្តុំមួយសំរាប់ស្វ័យសិក្សាមួយ និងឥរិយាបថថ្មីមួយចំពោះជីវិត ។

**កែច យ៉ារ**

> **"ដឹងឆ្លើយឡើងដល់ កូនសោតរៀនច្បាប់ ឡើងតែអាពុក**
> **ព្រាញគង់ឡើងស្រី ចេះរៀបដាក់ខ្លួន ប្រះដេកនាប់លត់**
> **ឡើងឥតបើគិត ៗ"**
>
> ច្បាប់បណ្តាំបិតា

# បច្ចេកទេសចោទសួរ

គរុកោសល្យវិទូបានពោលថា " ចេះសួរ គឺចេះរៀន " និង " ចេះសួរ គឺចេះបង្រៀន "

ដូចនេះ បានជាយើងទទួលស្គាល់ថា :

"ការចោទសួរ ជាមូលដ្ឋាននៃការគិតបែបរិះគន់ស្ថាបនា ការដោះស្រាយបញ្ហាលើពិភពលោកជាក់ស្តែងពិតៗ និងជាការរៀនមួយប្រកបដោយអត្ថន័យ " ។

## សំនួររបស់សិស្ស

សំនួររបស់សិស្សអាច រឺគួរតែប្រើវាសំរាប់សកម្មភាពចាប់ផ្តើមនៃសំនួរដទៃទៀតនៃការពិភាក្សា និង ការ ស្រាវជ្រាវ ។ ពិតមែនហើយ នៅក្នុងថ្នាក់រៀនដែលមានលក្ខណៈជាស្ថាបនា សំនួររបស់សិស្សច្រើនតែទាក់ទងទៅ នឹងខ្លឹមសារ ។ សិស្សគួរតែត្រូវបានលើកទឹកចិត្តអោយសួរ ដើម្បីជំរុញសិស្សអោយប្រឹងប្រែងអានសៀវភៅស្វែង យល់ពីលំនាំ រឺគំនិតរបស់នរណាម្នាក់ និង គួរលើកទឹកចិត្តដើម្បីអោយសិស្សស្វែងរកការពិត រឺ ភស្តុតាងដើម្បី បញ្ជាក់មតិរបស់នរណាម្នាក់នោះ ។ ការដែលសិស្សអាចចោទជាសំនួរ វាប្រសើរជាងសិស្សដែលមានសមត្ថភាព ឆ្លើយត្រូវសំនួររបស់គ្រូទៅទៀត ព្រោះថាចំនេះដឹងតែងបានមកអំពីការឆ្ងល់ រឺការចោទសួរ ។ សមត្ថភាពកំនត់ បាននូវបញ្ហា រួចហើយយកបញ្ហានោះមករៀបជាសំនួរ នេះជាភាពប៉ិនប្រសប់មួយ និងជាកូនសោរគន្លឹះសំរាប់ អភិវឌ្ឍសមត្ថភាពដោះស្រាយបញ្ហា និងសមត្ថភាពគិតបែបរិះគន់ស្ថាបនា ។ គ្រូបង្រៀនមានទំនួលខុសត្រូវក្នុង ការលើកទឹកចិត្តសិស្សអោយចោទជាសំនួរ និងជួយពួកគេអោយចេះប្រើពាក្យក្នុងការបង្កើតសំនួរអោយបានត្រឹមត្រូវ ហើយជួយពួកគេអោយមានចំនូលចិត្តក្នុងការរកចំលើយ នេះគឺជាលំនាំរៀនដ៏ចាំបាច់ដើម្បីកសាងមូលដ្ឋាន ចំនេះដឹងដែលកាន់តែកើតមានច្រើនទៅៗ ផ្អែកលើមាតិឆ្ងល់ សង្កេត ប្រមូលទិន្នន័យ បទពិសោធន៍ និងសន្និដ្ឋានបកស្រាយ ពន្យល់ពតិមានថ្មីនានានៅក្នុងស្ថានភាពថ្មី ។

## កំរិតសំនួរនៅក្នុងសៀវភៅសិស្ស

គរុកោសល្យវិទូទំនើបទទួលស្គាល់ថា ការអប់រំមានគុណភាពទៅបានលុះត្រាតែ សិស្សមានចិត្តចង់ចេះ ចង់ដឹង ព្រោះចំណង់ចេះដឹងនេះ ជាមូលដ្ឋានគ្រឹះនៃសកម្មភាពរៀនដទៃទៀត ។ ដើម្បីបណ្តុះទឹកចិត្តចង់យល់ដឹង របស់សិស្ស គ្រូត្រូវលើកទឹកចិត្តក្នុងការចោទ និងដោះស្រាយសំនួរទាំង បី កំរិតដូចខាងក្រោម :

**ក**- សំនួរកំរិតទាប រឺសំនួរចងចាំ :

ឧទាហរណ៍ : សមាជិកអាស៊ានមានប្រទេសណាខ្លះ ?

ដើម្បីឆ្លើយសំនួរទាំងនេះ សិស្សត្រូវការចំនេះដឹងធ្លាប់ឃើញ ធ្លាប់ឮ ។

**ខ**- សំនួរកំរិតខ្ពស់ រឺសំនួរបែបវិភាគ :

ឧទាហរណ៍ : ហេតុអ្វីបានជាទន្លេសាបសំបូរត្រី ?

ដើម្បីឆ្លើយសំនួរកិរិតនេះ សិស្សត្រូវគិតពិចារណារកហេតុ និងផល ។

**គ- សំនួរកិរិតអនុវត្ត រឺសំនួរទស្សទាយ :**

ឧទាហរណ៍ : តើត្រូវធ្វើយ៉ាងណា ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ?

ដើម្បីឆ្លើយសំនួរនេះ សិស្សត្រូវការវិភាគរកហេតុផលដែលបណ្ដាលអោយក្រីក្រកើតមានរួចហើយ រិះរកយុទ្ធសាស្ត្រអនុវត្ត ដើម្បីកាត់បន្ថយភាពក្រីក្រ ។

ឧទាហរណ៍ :(១)

| កិរិតចងចាំ | កិរិតវិភាគ (វាយតំលៃ) | កិរិតអនុវត្ត |
|---|---|---|
| ១- តើថ្ងៃនេះ អ្នកអានកាសែតបានចំនួនប៉ុន្មាន ? | ១- ហេតុអ្វីបានជាអ្នកអានកាសែតថ្ងៃនេះ ? | ១-ចូរអ្នកគិតមើល តើវាទៅជាយ៉ាងណា បើទៅថ្ងៃមុខពុំមានអ្នកអានកាសែតទៀត ? |
| | | |
| | | |
| | | |
| | | |
| | | |
| ២- តើថ្ងៃនេះ មានចំនងជើងអត្ថបទកាសែតអ្វីខ្លះ ? | ២- តើចំនងជើងកាសែត មានសារៈសំខាន់យ៉ាងណាខ្លះ ? | ២- តើអ្នកគិតថា រឿងរ៉ាវថ្មីនេះនឹងយកទៅចុះក្នុងកាសែតសំរាប់ថ្ងៃស្អែក រឺ ? |
| | | |
| | | |
| | | |
| | | |
| | | |

**" គ្រូដែលបង្រៀនមិនចេះចោទសួរសំនួរដល់សិស្ស ជាគ្រូខ្វះប្រសិទ្ធភាព "**

**បណ្ឌិតអ៊ុម_គុច**

(១) លោកអ្នកអាចរកឧទាហរណ៍ អោយបានច្រើនទៅទៀត ដើម្បីបំពេញកន្លែងនេះ ។




# លំហាត់បុរេសិក្សា

លំហាត់នេះមាន ៣ ផ្នែក ដែលមានគោលបំណងអប់រំបំរុងប្រយ័ត្ន :

១- កុមាររៀនសង្កេត ២- កុមាររៀនកត់សំគាល់ទ្រង់ទ្រាយ

៣- កុមាររៀនស្គាល់ចំនួន ។

នៅក្នុងទស្សនាវដ្ដីលេខ ១៤ នេះ យើងជូនលំហាត់ប្រភេទទី១ គឺកុមាររៀនសង្កេត ÷

ផាត់ពណ៌ លើខ្មៅដៃដែលមានប្រវែងស្មើនឹងខ្មៅដៃនេះ



ផាត់ពណ៌ លើខ្មៅដៃខ្លីជាងខ្មៅដៃនេះ



ផាត់ពណ៌ លើឆត្រណាដែលមានជំហរដូចឆត្រនេះ



ផាត់ពណ៌ លើឆត្រណាដែលមានជំហរដូចឆត្រនេះ



ផាត់ពណ៌ សត្វណាដែលតូចជាងសត្វឆ្កែនេះ



ផាត់ពណ៌ សត្វណាដែលធំជាងសត្វឆ្កែនេះ



ផាត់ពណ៌លើទូរថភ្លើងដែលរត់លើផ្លូវវៀច



ផាត់ពណ៌លើទូរថភ្លើងដែលរត់លើផ្លូវត្រង់



ផាត់ពណ៌លើកុមារខាងមុខគេដែលបានឆ្លងកាត់ទីបញ្ចប់




ផាត់ពណ៌លើកុមារខាងក្រោយគេដែលមិនបានឆ្លងកាត់ទីបញ្ចប់



# ល្បិចនៃវិចារ

- អនុមានរួម
- អនុមានញែក

ជាល្បិចនៃវិចារដែលអ្នកគ្រូ លោកគ្រូបានប្រើប្រាស់រាល់ថ្ងៃក្នុងដំណើរការនាំមេរៀននីមួយៗ ។

តើអ្នកគ្រូ លោកគ្រូនិយមប្រើល្បិចណាមួយជាងល្បិចណាមួយ ? ។ តើល្បិចណាមួយសមស្របនឹងគោលការណ៍ "សិស្សមជ្ឈមណ្ឌល" ជាង ? ។ សូមអ្នកគ្រូ លោកគ្រូធ្វើសេចក្ដីសំរេចចិត្តដោយខ្លួនឯង ។

តទៅនេះ យើងសាកល្បងអនុវត្តជំហានអភិវឌ្ឍរបស់ល្បិចទាំងនោះ ទៅលើមេរៀនវេយ្យាករណ៍ស្ដីពី "វគ្គសញ្ញារី បន្តក់" នៅថ្នាក់ទី ៥រឺ ទី ៦ ។

**<u>ករណីទីមួយ</u> ( អនុមានរួម )**

ក្នុងករណីនេះយើងចែកសិស្សជា ៦ ក្រុម សំរាប់ធ្វើការស្រាវជ្រាវ ។

| សកម្មភាពគ្រូ | សកម្មភាពសិស្ស |
|---|---|
| • គ្រូសួរសំនួរ : | |
| • ក្រុមទី ១ : | ១/ |
| ១-រកពាក្យដែលមានបន្តក់លើព្យញ្ជនៈនៃវគ្គ "ក" | • កក់-ខក់-ឆក់-ឆ្នក់ -សក់-លក់-កន្ទក់ - - - ល--- |
| ២-តើប្រើលើអក្សរប្រកបដែលជាស្រៈអ្វីខ្លះ? | • កាក់-ចាក់-ដាក់-ទាក់-ធ្លាក់-ជំពាក់-លាក់-រាក់-ល.<br>• កង់-គង់-អន្ទង់-លង់-សង់-ល--<br>២/ ស្រៈសំរាប់ប្រកប :<br>• ជាមួយមានស្រៈ អ និងស្រៈ អា<br>• ជាមួយ " ង " មានតែស្រៈ អ<br>ដូចនេះក្នុង ក វគ្គ : មានព្យញ្ជនៈ ក-ង ទទួលបន្តក់ |
| • ក្រុមទី ២ : ១/ រកពាក្យដែលមានបន្តក់លើព្យញ្ជនៈនៃវគ្គ " ច " | ១/ : ចាច់-សាច់-កាច់----<br>-------------- |
| ២/ តើប្រើលើអក្សរប្រកបដែលជាស្រៈអ្វីខ្លះ ? | ២/ : ស្រៈអា + ច - ញ |
| • ក្រុមទី ៣ :១/ រកពាក្យដែលមានបន្តក់លើព្យញ្ជនៈនៃវគ្គ " ដ " | - គ្មាន |

| | |
|---|---|
| ២/ តើប្រើស្រះអ្វីខ្លះក្នុងការប្រកប ? | - គ្មាន |
| • **ក្រុមទី ៤ : ១/** រកពាក្យដែលមានបន្តក់លើព្យញ្ជនៈនៃវគ្គ " ត " | ១/ : កត់-ចត់----<br>ចាត់-អត់-ទន់-ធ្ងន់-កាន់-គាន់--- |
| ២/ តើស្រះអ្វីខ្លះប្រើក្នុងការប្រកប ? | ២/ :ពាក្យផ្សំនឹងស្រះ អ-អា ប្រកបនឹងព្យញ្ជនៈ ត-ន |
| • ក្រុមទី ៥ : ១/ រកពាក្យដែលមានបន្តក់លើព្យញ្ជនៈនៃវគ្គ " ប " | ១/ : កប់-ទប់-ជប់-លប់---ល--<br>ឆាប់-រាប់-លាប់---ល--- |
| ២/ តើស្រះអ្វីខ្លះប្រើក្នុងប្រកប ? | ២/ :ព្យញ្ជនៈទទួលបន្តក់បានមាន " ប "<br>-ស្រះសំរាប់ប្រកបមាន អ-អា ។ |
| • ក្រុមទី ៦ : ១/ រកពាក្យដែលមានបន្តក់លើព្យញ្ជនៈនៃសេសវគ្គ | ១/ : កល់-គល់-ទល់-កង្វល់-<br>អំពល់-សល់---ល---<br>-គាល់-ពាល់-ចាស់-បាល់---ល--<br>+ចស់-ស្រស់-គស់-រស់-ពស់---ល--<br>-ចាស់-រាស់-ទាស់-អស់---ល--<br>២/ : ព្យញ្ជនៈទទួលបន្តក់បានមាន ល- ស |
| +<u>សួររួម</u> : | ស្រះសំរាប់ប្រកប : អ - អា |
| ១/ តើពាក្យទាំងនោះមានសំលេងដូចម្តេច? | - ធ្ងន់- ខ្លី |
| ២/ តើស្រះសំរាប់ប្រកបមានស្រះណាខ្លះ ? | - អ - អា |
| ៣/ តើព្យញ្ជនៈសំរាប់ប្រកបមានអ្វីខ្លះ ? | -ក-ង-ច-ញ-ត-ន-ប-ល-ស ( ៩តួ )[១] |
| ៤/ ចូរសរុបចំលើយខាងលើស្របជាមួយនេះ គ្រូជួយសំរួលបន្ថែមដើម្បីអោយបានវិធានពេញលេញ ។ | បន្តក់ ៏ រស្សសញ្ញាជាវណ្ណយុត្តិមួយប្រភេទសំរាប់ប្រើបំបែរសំលេងវែង អោយខ្លីកំបុតធ្ងន់ប្រើដាក់បានចំពោះតែលើតួអក្សរប្រកបរបស់ពាក្យខ្មែរដែលជាស្រះ អ-អា និងតួព្យញ្ជនៈ ៩ : ក-ង-ច-ញ-ត-ន-ប-ល-ស ។ |
| ៥/ ហេតុអ្វីពាក្យ សន្ទត ប្រាកដ កុសល វិកល--ល- មានសំលេងខ្លីកំបុតដោយគ្មានការប្រើបន្តក់ ។ | -ព្រោះពាក្យនេះ ជាពាក្យបាលីសំស្ក្រឹតក្លាយ ។ |
| +អោយសិស្សកត់ត្រាវិធាននេះ និងណែនាំអោយរៀនសូត្រចាំមាត់ ។ | |

(១)ក្រៅពីព្យញ្ជនៈ៩តួនេះ នៅមានព្យញ្ជនៈ "ជ" សំរាប់ប្រើតែពាក្យមួយម៉ាត់: គជ : វត្ថុជាដុំដូចជាពកមានសាច់រឹងដូចកែវ កើតមានក្នុងសរីរាង្គ រឺក្នុងក្បាលនៃសត្វទាំងឡាយ : គជខ្យង គជត្រី គជដំរី គជក្រៀល ។

## ករណីទី២ ( អនុមានវៀង )

| | |
|---|---|
| -គ្រូលើកនិយមន័យរបស់រស្សសញ្ញា រឺ បន្តក់ :<br>+និយមន័យ<br>រស្សសញ្ញា រឺ បន្តក់ រឺ សង្កត់ ជាវណ្ណយុត្តិមួយប្រភេទ មានសណ្ឋានប្រភេទកំបុតខ្លី ( ់ ) សំរាប់ប្រើបំបែរសំលេងវែងអោយខ្លីកំបុតធ្ងន់ ប្រើដាក់បានចំពោះតែតួអក្សរប្រកបរបស់ពាក្យខ្មែរ ដែលជាស្រៈ អ-អា ។<br>( វចនានុក្រមជួនណាត )<br>ឧទាហរណ៍ : កក > កក់<br>កាច > កាច់<br>ចាប > ចាប់<br>សល > សល់..........<br>+កំណត់សំគាល់ :<br>ចំពោះពាក្យ បាលី រឺ សំស្ក្រឹត ទោះបីមានសំលេងខ្លីកំបុតធ្ងន់ក្តី ក៏មិនត្រូវប្រើបន្តក់ឡើយ<br>ឧទាហរណ៍ : សទ្ធត - កល -កុសល-ប្រាកដ-ល--។<br>+ចែកសិស្សជាប្រាំពីរក្រុមសំរាប់ការពង្រឹងពុទ្ធិ : | - សិស្សកត់ត្រា |
| -ក្រុមទី១ : ចូររកពាក្យដែលមានបន្តក់នៅវគ្គ "ក" ស្រៈប្រើនៅក្នុងការប្រកប ។ | មើលឧទាហរណ៍ករណីទី១ និងមើលចំលើយខាងលើ ។<br>- |
| -ក្រុមទី២ : ពាក់ព័ន្ធនឹងវគ្គ " ច " | - |
| -ក្រុមទី៣ : ពាក់ព័ន្ធនឹងវគ្គ " ដ " | - |
| -ក្រុមទី៤ : ពាក់ព័ន្ធនឹងវគ្គ " ត " | - |
| -ក្រុមទី៥ : ពាក់ព័ន្ធនឹងវគ្គ " ប " | - |
| -ក្រុមទី៦ : ពាក់ព័ន្ធនឹងសេសវគ្គ | - |
| -ក្រុមទី៧ : រកពាក្យដែលមានសំលេងខ្លីកំបុតធ្ងន់ តែមិនបានប្រើរស្សសញ្ញា រឺ បន្តក់ | -<br>- |
| +ណែនាំអោយក្រុមនីមួយៗ រកពាក្យពាក់ព័ន្ធអោយបានយ៉ាងតិច១០ ទៅតាមលទ្ធភាពនៃវគ្គនីមួយៗ ។ | - |

# គណិតវិទ្យា

## គំនត់ចំនួន និងរកចំនួន

- " ពីអ្វីដែលបានស្គាល់ ទៅ អ្វីដែលមិនទាន់បានស្គាល់ "
- " ពីតិច ទៅ ច្រើន "
- " ពីងាយ ទៅ លំបាក "

ជាទស្សនទានដ៏ចំបងសំរាប់អភិវឌ្ឍការរៀន ការបង្រៀន ការតាក់តែងកម្មវិធីក៏ដូចជាការចងក្រងអត្ថបទនៃការសិក្សា ។

បច្ចុប្បន្ននេះ អ្នកគ្រូ លោកគ្រូមានសៀវភៅសិស្ស សៀវភៅគ្រូនៅក្នុងដៃដែលអ្វីៗទាំងនោះ ត្រូវបានរៀបចំជាលំដាប់លំដោយសមស្របទៅតាមគោលការណ៍ខាងលើនោះ ។

តទៅនេះ យើងសាកល្បងស្វែងរកកំនត់ចំនួន និងរកចំនួនសំរាប់បុរេសិក្សារហូតដល់បឋមសិក្សាដោយផ្អែកលើរូបភាពខាងក្រោមនេះ ÷



- ដើម្បីទៅកាន់សំបុកវា ស្រមោចខ្មៅត្រូវវារតាមផ្លូវដែលមានគ្រាប់ចំនួន ៥ ។

  ចូររកផ្លូវនោះ រួចគូសខ្មៅដៃនៅលើក្រដាស ។
- គូសចំនួនគ្រាប់នៅកន្លែងដែលមិនទាន់គ្រប់ ៦ នៅតាមផ្លូវស្រមោចក្រហម ។
- តើត្រូវគូសចំនួនគ្រាប់ប៉ុន្មានទៅត្រង់ចំនុចខ្វះនីមួយៗ ?

  ចំលើយ : ២, ៣, ៥, ៤
- តើនៅត្រង់ចំនុចនីមួយៗ ត្រូវធ្វើដូចម្តេចអោយបានចំនួន៦ ?

  ចំលើយ : ៤ + ២ = ៦

  ៣ + ៣ = ៦

  ១ + ៥ = ៦

  ២ + ៤ = ៦
- តើត្រូវធ្វើដូចម្តេច ដើម្បីអោយដឹងថាកន្លែងនីមួយៗខ្វះតាមចំនួននោះ ?

  ចំលើយ : ៦ -៤ = ២

  ៦ - ៣ = ៣

  ៦ - ១ = ៥

  ៦ - ២ = ៤
- នៅពេលដែលមិនទាន់គូសគ្រាប់បន្ថែម តើស្រមោចក្រហមឆ្លងកាត់គ្រាប់ប៉ុន្មាន ?

  ចំលើយ : ៤ + ៦ + ៣ + ១ + ២ = ១៦គ្រាប់
- នៅពេលគូសគ្រាប់បន្ថែមរួច តើស្រមោចក្រហមឆ្លងកាត់គ្រាប់ប៉ុន្មាន ?

  ចំលើយ : ១៦ + ( ២ + ៣ + ៥ + ៤ ) = ៣០គ្រាប់

  រឺ ៦ x ៥ = ៣០គ្រាប់

<u>*លំហាត់:*</u> ពិនិត្យគំនូរទំព័រ៣២ មានប្រអប់លេខ ⟨7⟩ ចំនួនពីរមានផាត់ពណ៌លឿង និងប្រអប់មួយចំនួនមានផលបូកស្មើនឹង ៧ ពុំទាន់មានផាត់ពណ៌នៅឡើយ ។ ចូរភ្ជាប់ប្រអប់លេខ ៧ មួយទៅលេខ ៧ មួយទៀត តាមប្រអប់ដែលមាន ផលបូកស្មើនឹង ៧ ដោយផាត់ពណ៌លឿងដែរ ។

- ធ្វើដូចគ្នា ចំពោះប្រអប់លេខ ⟨10⟩ ដោយផាត់ពណ៌ខៀវ ។
- ធ្វើដូចគ្នា ចំពោះប្រអប់លេខ ⟨9⟩ ដោយផាត់ពណ៌ក្រហម ។

ចំពោះប្រអប់លេខ ⟨8⟩ ក៏ដូចគ្នាដែរ តែប្រអប់ដែលភ្ជាប់ប្រអប់លេខ ៨ ទៅលេខ ៨ មួយទៀត សុទ្ធតែប្រអប់ទទេ⟨ ⟩ ។ ចូររកលេខដែលមានផលបូកស្មើនឹង ៨ ទៅបំពេញប្រអប់ទទេទាំងនោះ ។




- តើចំនួនប៉ុន្មាន បូកនឹងចំនួនប៉ុន្មាន ដើម្បីបានជាចំនួន ៧ ?
- តើចំនួនប៉ុន្មាន បូកនឹងចំនួនប៉ុន្មាន ដើម្បីបានជាចំនួន ១០ ?
- តើចំនួនប៉ុន្មាន បូកនឹងចំនួនប៉ុន្មាន ដើម្បីបានជាចំនួន ៩ ?
- តើចំនួនប៉ុន្មាន បូកនឹងចំនួនប៉ុន្មាន ដើម្បីបានជាចំនួន ៨ ? (សរសេរបំពេញប្រអប់ទំនេរលើរូបខាងលើ)

* <u>រៀនចាំមាត់</u> :

| | | | | |
|---|---|---|---|---|
| ៦ = ៣ + ៣ | ៧ = ៤ + ៣ | ៨ = ៤ + ៤ | ៩ = ៥ + ៤ | ១០ = ៥ + ៥ |
| ៦ = ៤ + ២ | ៧ = ៥ + ២ | ៨ = ៥ + ៣ | ៩ = ៦ + ៣ | ១០ = ៦ + ៤ |
| ៦ = ៥ + ១ | ៧ = ៦ + ១ | ៨ = ៦ + ២ | ៩ = ៧ + ២ | ១០ = ៧ + ៣ |
| | | ៨ = ៧ + ១ | ៩ = ៨ + ១ | ១០ = ៨ + ២ |
| | | | | ១០ = ៩ + ១ |

កែសំរួលដោយលោក ភែម យ៉ារ

# វេយ្យាករណ៍

## អំពីកិរិយាហេតុ

តើអ្នកគ្រូ លោកគ្រូត្រូវដឹកនាំសកម្មភាពសិក្សាដូចម្តេច ដើម្បីអោយសិស្សទទួលស្គាល់ថាពាក្យនេះ ជា កិរិយាហេតុ ?

សូមអ្នកគ្រូ លោកគ្រូសាកល្បងតាមដានការសិក្សាអំពីកិរិយាហេតុ និង ល្បិចបង្រៀនកិរិយានេះ ។

**I.សិក្សាសង្ខេបអំពីកិរិយាហេតុ :**

**១. អ្វីជាកិរិយាហេតុ ?**

កិរិយាហេតុ គឺកិរិយាស័ព្ទ ដែលសំដែងអំពើរបស់ប្រធានដែលធ្វើឡើងគ្រាន់តែជាដើមហេតុ ដើមចម ប៉ុណ្ណោះ ។

ឧទាហរណ៍:

- សេចក្តីព្យាយាមធ្វើអោយសំរេចជោគជ័យ ។
- លោកសាស្ត្រាចារ្យពន្យល់យើងពីរបៀបសំពះ ។

* គ្រប់កិរិយាហេតុ ជាកិរិយាសកម្ម ទោះជាមានប្រភពពីកិរិយាសុទ្ធសកម្មរឺអកម្មរឺគុណនាមក៏ដោយ ។

**២. កំនើតនៃកិរិយាហេតុ**

ផ្អែកតាមកំនើតរបស់វា កិរិយាហេតុមានពីរបែប ÷

កិរិយាប្រាប់ន័យបណ្តាល + កិរិយាសុទ្ធ/គុណនាម

បែបទី១ :

| |
|---|
| កិរិយាប្រាប់ន័យបណ្តាល + កិរិយាសុទ្ធ/គុណនាម |

ឧ ÷ ម្សៅសាប៊ូនេះ ធ្វើអោយខោអាវសស្អាត និងមានក្លិនក្រអូប

\+ ធ្វើអោយ សស្អាត , ធ្វើអោយមាន : កិរិយាហេតុ

បែបទី២ :

| |
|---|
| កិរិយាសុទ្ធ /គុណនាម + ផ្នត់កំលាយ |

ឧ ÷ មេរៀនថ្មីនេះ បង្រៀនយើងអំពីសិទ្ធិមនុស្ស ។

\+ បង្រៀន :កិរិយាហេតុ ( រៀន + [ បង់- ] )

**<u>សំគាល់:</u>**

- កិរិយាប្រាប់ន័យបណ្តាលមានដូចជា នាំអោយ, ធ្វើអោយ, ញ៉ាំងអោយ,......
- កិរិយាសុទ្ធអាចជាកិរិយាសុទ្ធសកម្មរឺ អកម្ម ។

## ៣. បំរើបំរាស់បរិបទបញ្ជាក់កិរិយាហេតុ

ខ្ញុំសន្មតថា លោកគ្រូ អ្នកគ្រូយល់ច្បាស់បែបទី១នៃកិរិយាហេតុ ( កិរិយាប្រាប់ន័យបណ្តាល + កិរិយា សុទ្ធ/គុណនាម ) ហើយ តែនៅស្ទាក់ស្ទើរចំពោះបែបទី២ ( កិរិយាសុទ្ធ/គុណនាម + ផ្នត់កំលាយ) ព្រោះជួនកាល ទំលាប់នៃការប្រើប្រាស់ភាសាក្នុងជីវភាពប្រចាំថ្ងៃ ពុំមានពេលអោយយើងនឹកគិតដល់ប្រភពកំនើតរបស់ពាក្យក្លាយមួយចំនួន ។ ដូចនេះ ខ្ញុំសូមលើកយកកិរិយាហេតុបែបទី២ មកស្រាយបំភ្លឺត្រួសៗផ្សំជាមួយចំនេះដឹងមាន ស្រាប់របស់លោកគ្រូ អ្នកគ្រូ ។

ឧ÷ ម្តាយផ្តេកកូនក្នុងអង្រឹង ។

ក្នុងកន្សោមកិរិយា "ផ្តេកកូនក្នុងអង្រឹង" នៃល្បះខាងលើ "ផ្តេក" ជាកិរិយាសកម្ម ។ តែ តើផ្តេកជាកិរិយា សុទ្ធ រឺកិរិយាហេតុ ?

- ដំបូង យើងរកមើលពាក្យរឹស(ពាក្យកំនើត) របស់ពាក្យផ្តេក ។ យើងឃើញថាផ្តេកមកពី ដេក គឺថាៈ

  ដេក + [ប-] > ផ្តេក ( ផ្នត់ដើម [ប-] ដូរជា [ ផ- ] )

- បន្ទាប់មក យើងបង្កើតល្បះពីរសំរាប់ធ្វើការប្រៀបធៀបគ្នា ។ ល្បះទី១ប្រើកិរិយាសុទ្ធ រឺគុណនាម ( ឧ÷ ដេក) ល្បះទី២ ប្រើកិរិយាមួយទៀត ដែលមានប្រភពចេញពីកិរិយាក្នុងល្បះទី១ ( ឧ÷ ផ្តេក < ដេក)

យើងបាន

ក. កូន ដេកក្នុងអង្រឹង ។

ខ. ម្តាយ ផ្តេកកូនក្នុងអង្រឹង ។

ក្នុងល្បះទាំងពីរនេះប្រាប់ថា "កូនដេកក្នុងអង្រឹង" ។ តែក្នុងល្បះ ខ កូនពុំមែនដេកដោយខ្លួនឯងទេ គឺមាន "ម្តាយ" ជាដើមហេតុ ។ ដូចនេះល្បះ ខ អាចពន្យល់បានថា÷ "ម្តាយផ្តេកកូនក្នុងអង្រឹង" មានន័យថា "ម្តាយនាំកូន (រឺញ៉ាំងកូន) អោយដេកក្នុងអង្រឹង" ។ ពោលគឺ÷ ផ្តេក មានន័យថា "នាំអោយដេក" ។

ឧទាហរណ៍ផ្សេងទៀត :

- ពង្រឹង គឺ ធ្វើអោយរឹង (គុ.)
- បន្សុទ្ធ គឺ ធ្វើអោយសុទ្ធ (គុ.)
- បណ្តើរ គឺ នាំអោយដើរ (កិ.)
- ប្តឹង គឺ ញ៉ាំងអោយដឹង (កិ.)
- បង្ខូច គឺ ធ្វើអោយខូច (គុ រឺ កិ.)

ម្យ៉ាងទៀត ប្រធានក្នុងល្បះក( កូន) បានធ្វើអំពើ "ដេក" ដោយពុំមានអ្នកបង្កដើមហេតុឡើយ ។ ឯប្រធាន ក្នុងល្បះខ( ម្តាយ) បានធ្វើអំពើមួយដែលជាដើមហេតុនាំអោយ "កូនដេក" តែពុំមែនធ្វើអំពើ "ដេក" ដោយខ្លួនឯង ទេ ។ ហេតុនេះកិរិយា

ដេក ពន្យល់ ពង្រីង បន្សុទ្ធ.....ដែលប្រធានរបស់វាធ្វើអំពើគ្រាន់តែជាមូលហេតុទាំងនេះ (ដេក យល់ រៀន រីង សុទ្ធ....) គឺជាកិរិយាសុទ្ធ រឺគុណនាម ។

**កំណត់សំគាល់ :** ប្រធាននៃល្បះដែលមានកិរិយាសុទ្ធក្លាយជាកម្មបទនៃល្បះដែលមានកិរិយាហេតុ ។

- កូនដេកក្នុងអង្រឹង ។ កូនជាប្រធាន
- ម្ដាយផ្ដេកកូនក្នុងអង្រឹង ។ កូនជាកម្មបទ

## II. ល្បិចបង្រៀនវេយ្យាករណ៍ កិរិយាហេតុ "ទំលាយ"

ខាងក្រោមនេះជាល្បិចបង្រៀនវេយ្យាករណ៍អំពីកិរិយាហេតុ "ទំលាយ" នេះគឺគ្រាន់តែជាបទពិសោធន៍មួយ ប៉ុណ្ណោះ ពុំមែនជាការបង្ខិតបង្ខំអោយលោកគ្រូ អ្នកគ្រូអនុវត្តតាមទាំងស្រុងឡើយ ។

១. សំភារៈ : ដបជ័រ២ (មួយធ្លាយ មួយទៀតនៅល្អ), កូនកាំបិតចុងស្រួច១

២. សមត្ថភាពចាំបាច់ : និយមន័យកិរិយាហេតុ, កិរិយាហេតុ=នាំអោយ....+ កិរិយាសុទ្ធ/គុណនាម

៣. ល្បិចដឹកនាំមេរៀនៈ

- គ្រូសរសេរល្បះពីរលើក្ដារខៀន រួចអោយសិស្សអាន
  - + ដបនេះធ្លាយ ។
  - + ខ្ញុំទំលាយដបនេះ ។
- ហៅសិស្សម្នាក់មកឈរនៅមុខសិស្សឯទៀត ហើយអោយអានល្បះទាំងពីរឡើងវិញ ដោយធ្វើសកម្មភាពផង÷
  - + ដបនេះធ្លាយ ។ (លើកបង្ហាញដបធ្លាយ)
  - + ខ្ញុំទំលាយដបនេះ ។ (យកកូនកាំបិតចាក់ទំលាយដបដែលមិនធ្លាយ)
- ណែនាំសិស្សអោយវិភាគទំរង់ល្បះទាំងពីរដើម្បីអោយបាន÷

| កន្សោមនាមប្រធាន | កន្សោមកិរិយា |
|---|---|
| ដបនេះ | ធ្លាយ |
| ខ្ញុំ | ទំលាយដបនេះ |

- គ្រូសួរ : ក្នុងល្បះទី១ អ្វីធ្លាយ ? ល្បះទី២ ?
  - +ល្បះទី១ : ដបធ្លាយ, ល្បះទី២ : ដបធ្លាយ ។
- គ្រូសួរ : ក្នុងល្បះទី២ "ខ្ញុំទំលាយដបនេះ" តើអាចមានន័យថា "ខ្ញុំធ្លាយ" បានទេ ?
  - + មិនបានទេ ។
- គ្រូសួរ : បើដូចនេះ តើ "ខ្ញុំទំលាយដបនេះ" មានន័យថាម៉េច ?

+ "ខ្ញុំទំលាយដបនេះ" មានន័យថា "ខ្ញុំធ្វើអោយដបនេះធ្លាយ" ។

- គ្រូសរសេរ ចាត់តាំងសិស្សអោយសរសេរលើក្តារខៀនដោយគូសបន្ទាត់ក្រោមពាក្យត្រូវរៀន÷

  + ខ្ញុំទំលាយដបនេះ = ខ្ញុំធ្វើអោយដបនេះធ្លាយ ។

- គ្រូសួរ : តើ "ទំលាយ" មានន័យដូចម្តេច ?

  + ទំលាយ គឺធ្វើអោយធ្លាយ ។

- គ្រូសួរ : តើកិរិយា "ធ្វើអោយធ្លាយ" ជាកិរិយាសុទ្ធ រឺកិរិយាហេតុ ?

  + កិរិយាហេតុ ។

- គ្រូសួរ : ទំលាយ=ធ្វើអោយធ្លាយ ។ បើ "ធ្វើអោយធ្លាយ" ជាកិរិយាហេតុ តើ "ទំលាយ" ជាកិរិយា ដូចម្តេច ?

- "ទំលាយ" ជាកិរិយាហេតុ ។

- គ្រូដឹកនាំសិស្ស អោយរកកិរិយាហេតុប្រភេទពាក្យកំលាយឯទៀត១ និងបង្ហាញទំរង់ផ្សំកំលាយខ្លះ ផង ។

  ឧ÷ ធ្លាក់ ទំលាក់ ស៊ី បន្ស៊ី ហើរ បង្ហើរ សាប បន្សាប....។

លោក ខៀវ ស៊ន

នាយកសាលាបឋមសិក្សាភូមិវាល

ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

**កំណត់សំគាល់:**

- មុនឆ្នាំ ១៩៩៧ មេរៀនកិរិយាហេតុប្រើសំរាប់ថ្នាក់ទី៥ ។

- ក្នុងសំនេរបស់ខ្ញុំ ខ្ញុំចាត់ទុកល្បិចបង្រៀននេះជាជំនួយ

ដល់ការពង្រឹងចំនេះដឹងរបស់លោកគ្រូ អ្នកគ្រូ និងពង្រឹង

ថែមទាំងការសិក្សាអំពីកិរិយាសកម្មនៅថ្នាក់ទី ៥ និងទី ៦ ។

"ចំណីអាហារ និងទឹកចាំបាច់ដល់ក្មេងយ៉ាងណា បរិយាកាសសប្បាយរីករាយនិងទិស្សមោភាស នៅពេលរៀនក៏ចាំបាច់ដល់សិស្សយ៉ាងនោះដែរ "។

ឈូ ឆោ



# វិធីបង្រៀនគំនូរដំបូង

ដោយលោក ប៉ាន់ ត្រា

ជាជំហានដំបូង នៅសាលាបឋមសិក្សាត្រូវណែនាំកុមារតូចៗអោយហាត់គូសគំនូសទាំង ៣ បែបគឺគំនូស ត្រង់ គំនូសកោង គំនូសរង្វង់ ព្រោះគំនូសទាំងនេះ ជាគំនូសដែលមានសារៈសំខាន់បំផុតក្នុងការគូររចនាជា រូបភាពផ្សេងៗ ឬជាផ្ទាំងគូរតែងលំអគ្រប់បែបគ្រប់យ៉ាង ។

ដើម្បីអោយសិស្សហាត់គូសគំនូសទាំងនេះ សិស្សត្រូវតាំងឥរិយាបថអោយបានត្រឹមត្រូវដូចខាងក្រោមនេះ÷



១- ឈរដាក់ដងខ្លួនអោយត្រង់ ។

២- ក្បាលត្រូវអោយត្រង់ កុំអោន កុំងើប កុំបេរ កុំផ្អៀងទៅឆ្វេងទៅស្តាំ

៣- កែងដៃទាំងពីរ ត្រូវអោយឃ្លាតចេញពីដងខ្លួន ។

៤- ម្រាមដៃស្តាំកាន់ខ្មៅដៃយ៉ាងបន្ធូរកុំសង្កត់ ។

៥- គូសគំនូសដោយលើកដៃអោយផុតពីក្រដាស ។

៦- ទប់ក្រដាសដោយម្រាមដៃឆ្វេង បណ្តោយស្របតាមគែមទៀត ។



៧- កុំបង្វែរ ឬបង្វិលក្រដាសចុះឡើង ។

៨- ជៀសវាងកុំប្រើជ័រលុប ។

ការណែនាំទាំង៨ខនេះ កុមារត្រូវប្រតិបត្តិអោយបានត្រឹមត្រូវប្រាកដប្រជាជាដាច់ខាត ពីព្រោះសេចក្តីណែនាំទាំងនេះមានការពាក់ព័ន្ធ ជាពិសេសក្នុងការរៀនហាត់គូសគំនូសទាំងអស់ជាចាំបាច់បំផុត ។

គំនូសដែលត្រូវដឹកនាំសិស្សអោយគូសជាដំបូងនោះ គឺគំនូសត្រង់ ។ គំនូសត្រង់ចែកចេញជា ៣ បែបគឺ គំនូស ត្រង់បញ្ឈរ ត្រង់ផ្តេក ត្រង់ទេរ ( ទៅឆ្វេង, ទៅស្តាំ) ។

## ការហាត់គូសគំនូសត្រង់បញ្ឈរ ត្រង់ផ្តេក ត្រង់ទេរ( ទៅឆ្វេង ទៅស្តាំ) :

មុននឹងអោយសិស្សហាត់គូសគំនូសទាំងនេះ ត្រូវអោយសិស្សតាំងឥរិយាបថខ្លួនអោយបានត្រឹមត្រូវតាមសេចក្តី ណែនាំទាំង ៨ ខ ពីខាងលើនោះជាមុនសិន ។

របៀបគូសគំនូសត្រង់ទាំង ៣ បែប :

- អោយសិស្សគូសគំនូសត្រង់បញ្ឈរ ( គូសពីលើចុះមកក្រោម ) ( រូបទី១)
- គូសគំនូសត្រង់ផ្តេក ( ចាប់ពីឆ្វេងទៅស្តាំ) ( រូបទី២)
- គូសគំនូសត្រង់ទេរទៅឆ្វេង ( ចាប់ពីឆ្វេងឆៀងចុះទៅស្តាំ) ( រូបទី៣)
- គំនូសត្រង់ទេរទៅស្តាំ ( ចាប់ពីស្តាំឆៀងចុះទៅឆ្វេង) ( រូបទី៤)

- គំនូសនីមួយៗ ត្រូវដឹកនាំសិស្សអោយហាត់គូស លុះត្រាតែបានត្រង់គួរសមសិន មុននឹងចាប់គូសគំនូស ថ្មីមួយទៀត ទោះបីប្រើពេលយូរបន្តិចក៏ដោយ ។


រូបទី១


រូបទី២


រូបទី៣


រូបទី៤

**ការយកគំនូសទាំង ៣ បែបនេះទៅរចនាជារូបភាពផ្សេងៗ :**

កាលណាសិស្សគូសគំនូសត្រង់ទាំង ៣ បែបនេះ បានល្អគួរសមហើយ ត្រូវជួយដឹកនាំសិស្សអោយយក គំនូសទាំងនោះទៅប្រើក្នុងការគូសផ្សំអោយបានទៅជារូបភាពងាយៗ ដែលសិស្សធ្លាប់ឃើញធ្លាប់ស្គាល់ ។

គំនូសដែលនាំអោយគូរជាដំបូងនេះហៅថា÷ "គំនូសគូរតាម" គឺរូបភាពអ្វីមួយដែលត្រូវដាក់អោយសិស្សគូរ លោកគ្រូ អ្នកគ្រូ ត្រូវគូររបស់នោះនៅលើក្តារខៀនជាមុន ហើយដឹកនាំសិស្សអោយគូររូបភាពនោះជាវត្ថុដូចខាង ក្រោមនេះ ។

ឧទាហរណ៍ : រូបមូកស្លឹកត្នោត ។

គ្រូត្រូវគូររូបមូកស្លឹកត្នោតនេះនៅលើក្តារខៀនជាមុន



- ដំបូងត្រូវអោយសិស្សរៀនមើលពិនិត្យសង្កេត និងប្រមាណមើលរូបមូកស្លឹកត្នោតនោះ ហើយចោទសួរ ជាសំនួររិះរកដោយមាត់ដល់សិស្សដូចខាងក្រោមនេះ ។

**សំនួររិះរកដោយមាត់ :**

**ក**- រូបនេះគឺជាអ្វី ?

**ខ**- ចូរអ្នកពិនិត្យមើលលើរូបមូកស្លឹកត្នោតនេះ មានគំនូសត្រង់បញ្ឈរឬទេ ? មានប៉ុន្មាន ?

**គ**- ចូរអ្នកឡើងទៅចង្អុលមើល គំនូសណាខ្លះដែលជាបន្ទាត់ត្រង់បញ្ឈរនោះ ?

**ឃ**- គំនូសត្រង់បញ្ឈរទាំងនោះប្រវែងស្មើគ្នាឬទេ ? សំគាល់អ្វី ?

ង- ចូរអ្នកពិនិត្យមើលម្តងទៀត តើក្រៅអំពីគំនូសត្រង់បញ្ឈរទាំងពីរនេះ តើមានគំនូសអ្វីដទៃទៀតដែរ ? ជាគំនូសអ្វី ? ប៉ុន្មាន ?

ច- អោយសិស្សឡើងទៅចង្អុលបង្ហាញបន្ទាត់ត្រង់ផ្តេកទាំង ៣ នោះនៅលើក្តារខៀន ។

ឆ- គំនូសត្រង់ផ្តេកទាំង ៣ នេះ មានបណ្តោយស្មើគ្នាឬទេ ?

ជ - គំនូសត្រង់ផ្តេកខាងលើប្រវែងស្មើនឹងគំនូសត្រង់ផ្តេកបន្ទាប់ដែរឬទេ ? ស្មើនឹងគំនូសត្រង់ផ្តេកក្រោម បំផុតដែរឬទេ ?

ឈ- គំនូសត្រង់ផ្តេកខាងលើសំគាល់អ្វី ? គំនូសត្រង់ផ្តេកបន្ទាប់សំគាល់អ្វី ? គំនូសត្រង់ផ្តេកខាងក្រោម បំផុតសំគាល់អ្វី ?

- ពេលរៀនគូរថ្ងៃដំបូង គ្រាន់តែណែនាំសិស្សអោយរៀនមើលពិនិត្យសង្កេត ប្រមាណ និងបញ្ជាក់ គំនូសទាំងអស់ដែលផ្សំគ្នារចនាជារូបមួកនោះប៉ុណ្ណោះបានហើយ មិនត្រូវបង្ខំសិស្សអោយគូររូបនោះតែម្តងដោយ ឥតស្គាល់គំនូស និងប្រយោជន៍របស់គំនូសដែលយកមកប្រើដើម្បីរចនាជារូបមួកនោះឡើយ ។

**<u>របៀបគូរ:</u>**

**វគ្គទី ១:** ក- គ្រូគូសនៅលើក្តារខៀន គំនូសត្រង់បញ្ឈរពីរ ឃ្លាតឆ្ងាយពីគ្នាបន្តិច ។

ខ - អោយសិស្សឡើងទៅគូសលើក្តារខៀននូវគំនូសត្រង់បញ្ឈរពីរ តាមគំរូដែលគ្រូបានគូស ហើយនោះ ។

គ- អោយសិស្សទាំងអស់ពិនិត្យមើល ហើយនាំគ្នារិះគន់គំនូសត្រង់បញ្ឈរពីរដែលគូសដោយមិត្ត របស់ខ្លួននោះ ។



បើមានទាស់ខុសបែបណាត្រូវអោយសិស្សឡើងទៅកែដោយមានការណែនាំអំពីគ្រូ ។

បើគំនូសនោះ សិស្សបានគូសល្អត្រឹមត្រូវហើយ គ្រូត្រូវនិយាយសរសើរលើកទឹកចិត្តសិស្សនោះដោយ ប្រការផ្សេងៗ ។

ឃ- អោយសិស្សទាំងអស់គ្នា គូសគំនូសត្រង់បញ្ឈរទាំងពីរ លើក្តារឆ្នួន ឬក្នុងសៀវភៅ ក្រោមការត្រួតពិនិត្យ របស់គ្រូ ។

**វគ្គទី ២:** ង- គ្រូគូសគំនូសត្រង់ផ្តេក៣ភ្ជាប់គំនូសត្រង់បញ្ឈរទាំងពីរនោះ ( គំនូសត្រង់ផ្តេកខាងលើ គឺបាត របស់មួក- គំនូសត្រង់ផ្តេកទី ២ គឺរង្វាន់មួក- គំនូសត្រង់ផ្តេកទី៣ គឺហាមមួក ) ។



ច - អោយសិស្សឡើងទៅគូសនៅលើក្តារខៀនបន្ថែមលើគំនូសបញ្ឈរពីរដែលមិត្តខ្លួនបានគូសពី មុន ។

ឆ - អោយសិស្សទាំងអស់គូសគំនូសត្រង់ផ្តេកទាំង៣នោះបន្ថែមលើគំនូសត្រង់បញ្ឈរទាំងពីរនោះ លើក្តារឆ្នួន ឬក្នុងសៀវភៅដូចគំរូលោកគ្រូ-អ្នកគ្រូ ។

**វគ្គទី ៣:** ជ- គ្រូគូសឆូតជាគំនូសតូចៗ លើតួមួក ។

ឈ-អោយសិស្សឡើងទៅគូសឆ្នូតតាមលោកគ្រូ អ្នកគ្រូ លើតួម្នកដែលមិត្តខ្លួនបានគូសហើយ
នោះ ។

ញ- អោយសិស្សទាំងអស់  គូសគំនូសតូចៗនោះនៅលើតួម្នកដែលខ្លួនបានគូរលើក្ដារឆ្នួន ឬក្នុង
សៀវភៅ ។

- នៅពេលដែលគូសគំនូសណាមួយលើក្ដារខៀន គ្រូត្រូវនិយាយពន្យល់អំពីប្រយោជន៏ និងតួនាទីរបស់ គំនូសនោះ អោយសិស្សបានស្គាល់បានយល់ច្បាស់លាស់ផង ។
- ក្រោយពីសិស្សឡើងគូសបន្ទាត់តាមគំរូ លោកគ្រូ-អ្នកគ្រូ នៅលើក្ដារខៀន គ្រូត្រូវអោយសិស្សទាំង អស់ពិនិត្យមើលគំនូសរបស់មិត្តខ្លួននោះ ហើយនាំគ្នាកែ ( បើសិនជាមិនទាន់ត្រឹមត្រូវ ) ។ ធ្វើដូច្នេះ គឺដើម្បីអោយ សិស្សទាំងអស់គ្នាចេះនាំគ្នារកកំហុស ហើយចេះនាំគ្នាកែអោយបានត្រឹមត្រូវវិញ ។

គំនូរដែលសិស្សតូចៗទើបតែចាប់ហាត់គូរជាដំបូងនេះ ឃើញថាមានការលំបាកខ្លះជាប្រាកដ ។ ហេតុនេះ លោកគ្រូ-អ្នកគ្រូមានអំណត់ពុះពារក្នុងការណែនាំសិស្សអោយគូរតាមសំរួលមិនត្រូវបង្ខំអោយសោះ ។

បើគំនូសនោះ សិស្សគូរពុំបានត្រឹមត្រូវ ឬពុំទាន់ហើយក្នុងមួយពេលនោះ ត្រូវអោយសិស្សគូរគំនូរដដែលនេះបង្ហើយនៅលើកក្រោយទៀត ។

**<u>កំណត់សំគាល់:</u>**

រូបភាពដែលណែនាំសិស្សអោយគូរជាដំបូងនេះ គឺត្រូវគូររបស់ដែលដាក់កំពស់ស្មើនឹងបន្ទាត់ខ្សែភ្នែក(Ligne de vue) ឬបន្ទាត់ជើងមេឃ (Ligne horizontale) ព្រោះរបស់ដែលវាស់កំពស់ស្មើនឹងបន្ទាត់ខ្សែភ្នែកនេះសុទ្ធ តែកើតឡើងដោយបន្ទាត់ត្រង់ទាំងអស់ ទោះបីរបស់នោះជារបស់រាងជ្រុង ឬរាងមូលទ្រវែង លើកលែងតែរបស់ ណាដែលមានរាងកោង ឬមូលដូចបាល់ជាដើម ។

ដើម្បីអោយលោកគ្រូ-អ្នកគ្រូយល់ច្បាស់ យើងសូមជូនការមើលឃើញវត្ថុដែលដាក់កំពស់ស្មើនឹងបន្ទាត់ខ្សែ ភ្នែក។




ប្រអប់ដីស




កែវទឹក

<u>**កំណត់ចំណាំ:**</u>

- ប្រអប់ជីសដែលជាវត្ថុរាងជ្រុងនេះ បើដាក់កំពស់ស្មើនឹងបន្ទាត់ខ្សែភ្នែក ដូចនេះត្រូវមើលឃើញតែមួយជ្រុងទេ ហើយជ្រុងនោះកើតឡើងដោយបន្ទាត់ត្រង់ បញ្ឈរ ២ និងផ្ដេក ៣ ។(រូបទី ១)

- កែវទឹកដែលជាវត្ថុរាងមូលទ្រវែងរីកល្មើមក្រោម បើដាក់កំពស់ស្មើនឹង បន្ទាត់ខ្សែភ្នែក ដូចនេះត្រូវមើលឃើញផ្នែក ដែលបិតនៅចំភ្នែកយើងដែលកើត ឡើងដោយបន្ទាត់ទេរ ២ និងបន្ទាត់ផ្ដេក ២ ។(រូបទី ២)

ដោយសិស្សនៅថ្នាក់ទី១នេះ ទើបតែរៀនគូសគំនូសត្រង់ទាំង ៣ បែបប៉ុណ្ណោះ មិនត្រូវអោយគូររបស់ណា ដែលមានរាងរៅខុសអំពីគំនូសទាំងនេះឡើយ ហើយត្រូវអោយសិស្សគូរតែរបស់ណាដែលដាក់ស្មើនឹងបន្ទាត់ខ្សែ ភ្នែក ព្រោះវត្ថុទាំងនោះសុទ្ធតែកើតឡើងដោយបន្ទាត់ត្រង់ទាំងអស់ ។

នៅខាងក្រោមនេះ យើងជូនរបៀបគូរគំនូរងាយៗខ្លះជាឧទាហរណ៍÷

## គំនូរកើតឡើងដោយគំនូសត្រង់បញ្ឈរនិងត្រង់ផ្ដេកៈ

ដើម្បីអោយមានការងាយស្រួលក្នុងការគូររូបភាពទាំងនេះ យើងត្រូវគូរចែកជាវត្ថុដូចមានគំនូរជាឧទាហរណ៍ខាងក្រោមនេះ ។

(សូមលោកគ្រូ-អ្នកគ្រូអោយសិស្សដាក់ពណ៌លើគំនូរដែលគូរហើយនោះកុំបីខាន ។ របៀបផាត់ពណ៌នេះ សិស្សមានសេរីភាពដាក់តាមចំណង់របស់ខ្លួន មិនបាច់ត្រូវទៅ តាមការដាក់ស្តែងឡើយ) ។

### ក- រូបភាពគំនូសត្រង់បញ្ឈរ និងត្រង់ផ្ដេកៈ

វគ្គទី ១ វគ្គទី ២ វគ្គទី ៣

៩.


១០.


១១.


១២.


១៣.


១៤.


១៥.


ខ-រូបភាពគំនូសត្រង់បញ្ឈរ ត្រង់ផ្ដេក និងត្រង់ទេរ:

១.


២. 

៣. 

៤. 

៥. 

នៅលេខក្រោយ ខ្ញុំនឹងជំរាបជូនពីគំនូសកោង និងរង្វង់ជាបន្តបន្ទាប់ ។

ៜៜៜៜៜ

**ហេតុអ្វីបានជាបរិស័ទយកផ្កាឈូកសំរាប់ពុទ្ធបូជា ?**

ព្រះពុទ្ធអង្គបានប្រៀបមនុស្សលោកទៅនឹងផ្កាឈូកបួន ៖

- បឹងតំណាងវាលវដ្តសង្សារពោរពេញទៅដោយចំណង់គ្រប់បែបយ៉ាងដូចជា : លោភៈ ទោសៈ មោហៈ រាគៈ ប្រទាក់ប្រទាញបុគ្គលអោយវិលវល់ក្នុងវដ្តសង្សារដដែលៗ ។
- ផ្កាឈូកលិចក្នុងទឹក ប្រៀបបាននឹងបុគ្គលត្រូវតណ្ហាសង្កត់រឹតខ្លួនពុំរួច ។ នេះជាជំពូកបុគ្គលអវិជ្ជាពុំអាចទទួលការអប់រំរបស់ព្រះអង្គបានទេ ។
- ផ្កាឈូកនៅត្រឹមផ្ទៃទឹក ប្រៀបបាននឹងបុគ្គលដែលអាចទទួលការអប់រំបានយ៉ាងងាយ ព្រោះពុំទាន់ទទួលការរឹតត្បិតពីតណ្ហានៅឡើយ ។

# ប្រវត្តិវិទ្យា

# ប្រទេសកម្ពុជាចុងសម័យអង្គរ

ថ្នាក់ទី ៥

- មេរៀនទី ០៤
- សៀវភៅសិស្ស ទំព័រ ១៦-១៧
- សៀវភៅគ្រូ ទំព័រទី ៣៣-៣៥

<u>អត្ថបទជំនួយ:</u>

**ក/ ភាពច្របូកច្របល់ :**

គេពុំបានដឹងច្បាស់ថា ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ចូលទីវង្គតក្នុងឆ្នាំណាទេ ។ តែគេដឹងថាព្រះបាទឥន្ទ្រវរ្ម័នទី២ ជាព្រះរាជបុត្របានឡើងស្នងរាជ្យ ។

នៅដើមរាជ្យរបស់ព្រះអង្គ ព្រះអង្គទ្រង់ចាត់អោយទ័ពខ្មែរសហការជាមួយចាម ដើម្បីវាយយួនដៃវៀតក្នុង ឆ្នាំ ១២១៨ ។ លុះដល់ឆ្នាំ ១២២០ ខ្មែរបានដកថយពីប្រទេសចម្ប៉ា ដោយខ្លួនឯងគឺប្រហែលដោយការរើបំរះនៃ ជនជាតិថៃ បង្កើតសុខោទ័យក្នុងឆ្នាំ ១២២០ ដោយស្តេចរាមាកំហែង ។

គេពុំបានដឹងថា ព្រះបាទឥន្ទ្រវរ្ម័នទី ២ សុគតក្នុងឆ្នាំណាទេ ។ គេដឹងថា ក្រោយស្តេចឥន្ទ្រវរ្ម័នទី២ ចូលទីវង្គត ស្តេចជ័យវរ្ម័នទី៨បានឡើងគ្រងរាជ្យ ។ ក្សត្រអង្គនេះ បានលើកតំកើងព្រហ្មញ្ញសាសនាជាថ្មី ជាហេតុបណ្តាល អោយប៉ះទង្គិចគ្នាជាខ្លាំងរវាងពុទ្ធនិយម និងអ្នកព្រហ្មនិយម ។ នេះជាកត្តាធ្វើអោយមានការបែកបាក់សាមគ្គីផ្ទៃ ក្នុង។ ចំនែកថៃ ដែលទើបកកើតបានជារដ្ឋនោះក៏ចេះតែរកឧបាយ ដើម្បីពង្រាតទឹកដីរបស់គេ ។

បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី ៨ បានសុគតទៅ (ឆ្នាំ១២៩៥) ភាពច្របូកច្របល់ដណ្តើមរាជ្យចេះតែមានជា បន្តបន្ទាប់ធ្វើអោយអាណាចក្រកម្ពុជាចេះតែចុះខ្សោយជាលំដាប់ រហូតដល់មានបដិវត្តន៍របស់នាយត្រសក់ផ្អែម រវាងឆ្នាំ ១៣៤០ ដែលជាបដិវត្តន៍នយោបាយ និង សាសនា ព្រោះចាប់ពីពេលនោះមកព្រហ្មញ្ញសាសនាបានអស់ ឥទ្ធិពល ហើយរាជ្យវង្សក្សត្រខ្មែរក៏ផុតរលត់ចាប់ពីពេលនោះមកដែរ ។

**ខ/ ទំនាក់ខ្មែរ-សៀម :**

ក្នុងឆ្នាំ ១២២០ នៃគ.ស សៀមបានបង្កើតរដ្ឋសុខោទ័យ ។ លុះដល់ឆ្នាំ ១៣៥០ ស្តេចសៀមបានលើករាជ ធានីមកតាំងនៅអយុធ្យាវិញ ដែលងាយស្រួលនឹងពង្រាតទឹកដីចូលមកក្នុងរាជាណាចក្រកម្ពុជា ។

• ឆ្នាំ១៣៥២ ក្នុងរាជស្ដេចលំពង្សរាជា ( ចៅតាត្រសក់ផ្អែម) សៀមវាយលុកចូលមកដល់ទីក្រុងអង្គរ ប្រមូលយកវត្ថុមានតំលៃ និងចាត់តាំងក្សត្រសៀមអោយត្រួតត្រាអង្គរ ។ លុះដល់ឆ្នាំ ១៣៥៧ ក្សត្រខ្មែរមួយអង្គ ព្រះនាមស្រីសូរិយោវង្សទី១ បានកំចាត់សៀមអោយចេញពីក្រុងអង្គរ ដណ្ដើមយកបាននគររាជសីមា ។

• ឆ្នាំ ១៣៩៤ ក្នុងរាជស្ដេចធម្មសោក សៀមវាយលុកអង្គរជាថ្មីម្ដងទៀត ។ ដោយមានខ្មែរខ្លះ ចូលដៃជាមួយសៀម សៀមវាយយកអង្គរបាន ហើយចាត់តាំងព្រះរាជបុត្រសៀមព្រះនាមពញាកែ្រកសោយរាជ្យនៅក្រុង អង្គរ ។ ឆ្នាំ ១៤០១ ក្សត្រខ្មែរព្រះនាមស្រីសូរិយោវង្សទី២ បានកំចាត់សៀមអោយចេញពីអង្គរ ។

• ឆ្នាំ ១៤២០ បរមសោករាជស្ដេចសៀមបានវាយលុក និងត្រួតត្រាអង្គរជាលើកទី ៣ ។
ស្ដេចពញាយ៉ាតបានរំដោះអង្គរពីកណ្ដាប់ដៃសៀមក្នុងឆ្នាំ ១៤២១ ។

**ខោល គុន**

• ប្រាសាទក្នុងសម័យអង្គរ រចនាបថព្រះគោ : ប្រាសាទព្រះគោ ប្រាសាទបាគង ប្រាសាទលលៃ ។

• ប្រាសាទក្នុងសម័យអង្គរ រចនាបថភ្នំគូលែន : ប្រាសាទដំរីក្រាប ប្រាសាទទន្ទឹងស្លាប់ ប្រាសាទរូបអារក្ស ប្រាសាទថ្មដាប់ ប្រាសាទគគីរ ប្រាសាទអ្នកតា ។



# នាទីកំនាព្យនិងកំសាន្ត

* ពិភពលោកប្រកបដោយពហុសណ្ឋាន ។ ដើមឈើមួយកង់ រឺគល់ឈើមួយត្រូវបានជារាងតុ កៅអី ជើងម៉ា មួយ ។ ជាងតុ កៅអីកំពុងបញ្ចេញរាងបែបធម្មជាតិនេះដោយឈើបេង រឺនាងនួន ។ ដូចនេះ អ្នកអាចជ្រើសរើសតុ ជើងម៉ាតាមបែបរាងធម្មជាតិនេះក៏បាន ។ បើពុំដូចនោះទេ អ្នកអាចស្រាវជ្រាវរករាងបែបណាក៏បានយ៉ាងសំបូរ បែប ដោយគ្រាន់តែអ្នកគូសភ្ជាប់រង្វង់ណាមួយក្នុងគំនូសរឹមរវាមខាងក្រោមនេះ ។ឧទាហរណ៍:



* ប្រសិនបើ ផែនដីទាំងមូលមានទំងន់១លានតោន* ហើយគេសង់សំនង់មួយលើនោះមានចំនួន៣០ពាន់តោន តើផែនដីទាំងមូលមានទំងន់ប៉ុន្មាន ?

**<u>កំនត់សំគាល់:</u>** ការដោះស្រាយចំនោទខាងលើនេះពាក់ព័ន្ធនឹងរូបមន្ត "គ្មានអ្វីកើត គ្មានអ្វីបាត់ អ្វីៗត្រូវបំលែង" ។

**កែវ យ៉ារ**

* ផែនដីទំងន់ប្រមាណ ៦៦ x ១០$^{២០}$តោន ។ មានផ្ទៃសរុប = ៥១០ លាន $Km^2$ . ផ្ទៃដី ១៤៩ លាន $Km^2$. ចែកចេញជា ១៩២ រដ្ឋឯករាជ្យ និងមានប្រជាជនសរុប ៦ ពាន់លាននាក់ ។

# បុណ្យអុំទូក

ខែកត្តិកទសម្ញា ពលរដ្ឋកម្ពុជា សាទរអបអរ
រំលឹកគុណមេ -គង្គាគុណបវរ ក្រោមចន្ទគោចរ
ត្រចះមេឃា ។

កម្មវិធីរមបី ទឹកគុណទឹកដី ទឹកគុណយោធា
អុជទៀនព្យាករណ៍ ភ្លៀងព្រះពិរុណា អនាគតកម្ពុជា
នារដូវថ្មី ។

វរៈមេការ មាតាជលសារ នាំល្បាប់ដីដី
ចិញ្ចឹមផលា ពាសពេញបុរី ខេមរៈប្រុសស្រី
ដឹងគុណជានិច្ច ។

យុទ្ធជនអង់អាច រិទ្ធីអំនាច ពួតដៃកំទេច
គ្រប់មារសត្រូវ ត្បូងជើងកើតលិច ជោគជ័យសំរេច
ការពាររដ្ឋា ។

អារម្មណ៍រិះគិត ស្រោចស្រង់ជីវិត បងប្អូនខេមរា
ក្លាហានសំរុក តាមដងជលសារ ទុកក្តីមរណា
ពុំស្មើប្រទេសជាតិ ។

រីករាយជានិច្ច ភ្ជាប់ភារកិច្ច ភ្លេចសាច់ភ្លេចញាតិ
សក្តិសមកុលបុត្រ បរិសុទ្ធស្អាត ទាំងប្រុសមារយាទ
ចារជាប់ដរាប ។

អ្នកនិពន្ធ: ..................................(១)

(១) __គន្លឹះសំគាល់:__ ប្រសិនបើ អ្នកចង់ស្គាល់អ្នកនិពន្ធ សូមអ្នកផ្គុំអក្សរទី១នៃល្បះនីមួយៗ លើកលែងល្បះទី៥ ដោយត្រូវផ្គុំជាមួយស្រៈរបស់ព្យាង្គទី ១ រួចដាក់មូសិកទន្តលើព្យញ្ជនៈទី១នៃល្បះទី ៤ ។

**កំណាព្យ**

**ពាក្យ ៧**

# មោហាគតិ

១. ទាបខ្ពស់ប្រហែលៗគ្នា ច្មៀសពាក្យនិន្ទាមិនផុតទេ
មានពាក្យសរសើរ តិះដៀលដេរ មាសមេតោងមើលព្រះអាទិត្យ ។

២. ព្រះច័ន្ទ ទឹកភ្លៀង ហើយនិងខ្យល់ វាទៅមិនដល់ វាខឹងពិត
ចំណង់បើយើងនៅទាបជិត ធ្វើជាបណ្ឌិត ចិត្តឋិតថេរ ។

៣. អាទិត្យ និងច័ន្ទ លើអាកាស បំភ្លឺអោយច្បាស់ គង់គេជេរ
រួចពាក្យនិន្ទា តែផ្ដាយទេ គ្មានបំភ្លឺគេ គេមិនស្អប់ ។

៤. ពួកពាលសត្រូវនឹងពាក្យពិត ស្រឡាញ់ងងឹតគ្មានធុញថប់
ស្រទំដោយសារ ពពកគប់ គង់ខ្យល់ត្រឡប់ ផាត់ចេញទៅ ។

៥. ធម្មតាជនពាលក្នុងលោកិយ មានគំនិតខ្លី ឆោតល្ងង់ខ្លៅ
ភ្លៀងពេក រាំងពេក មកម្ដងម៉ៅ ត្រជាក់ និងក្ដៅ ក៏ខឹងដែរ ។

៦. ហៃកូនសម្លាញ់មាសឪពុក កូនកុំកើតទុក្ខ ដោយគេជេរ
កាន់ពុទ្ធសាសនា អោយឋិតថេរ កុំអោយវៀចវេរកាន់អោយខ្ជាប់ ។

ស្រាវជ្រាវពីឯកសារបុរាណខ្មែរ
ដោយលោក : **ជេង កែន**
អគ្គលេខាធិការនៃគណៈកម្មាធិការស.ប.ស.ខ
និង ជាអនុប្រធានការិយាល័យនៃមន្ទីរអប់រំ យុវជន
និងកីឡា ខេត្តកំពង់ឆ្នាំង ។

**អគតិ ៤ យ៉ាង**

**១. ឆន្ទាគតិ** **២. ទោសាគតិ**

**៣. មោហាគតិ** **៤. ភយាគតិ**



លោកគ្រូ អ្នកគ្រូទាំងអស់ប្រហែលធ្លាប់ជួបប្រទះហើយ តើបានចាប់អារម្មណ៍ហើយឬនៅទៅលើការសរសេរលេខ ដោយបន្ថែមសូន្យសំរាប់ចុះកាលបរិច្ឆេទ ថ្ងៃ ខែ ឆ្នាំកំណើតឬកំនត់ចំនួនវត្ថុតំលៃផ្សេងៗ ។

ចំពោះសំនេរទាំងនេះ យើងហាក់បីដូចមិនទាន់ចាប់អារម្មណ៍នៅឡើយទេថា តើពិតជាត្រឹមត្រូវតាមក្បួនហើយឬនៅ ?

ដូច្នេះសូមលោកគ្រូ អ្នកគ្រូ ផ្ដោតអារម្មណ៍លើរឿងនេះជាមួយខ្ញុំម្ដង ។ ឧទាហរណ៍: ខ្ញុំកើតនៅថ្ងៃទី ៩ ខែ មិនា ឆ្នាំ ១៩៧១ ហើយខ្ញុំសរសេរជាតួលេខដោយបន្ថែមសូន្យទៅលើថ្ងៃ និង ខែថា ០៩-០៣-១៩៧១ តើការបន្ថែមសូន្យទៅលេខ៩ និងលេខ៣នេះត្រឹមត្រូវដែរឬទេ ?

ខ្ញុំសូមបកស្រាយថា ការបន្ថែមសូន្យទៅលើលេខ ៩ ពិតជាត្រឹមត្រូវ ហេតុអ្វីបានជាត្រូវបន្ថែម ? ព្រោះក្នុងមួយខែមាន ចំនួនរហូតដល់ ៣១ ថ្ងៃ ។ ចាប់ពីថ្ងៃទី ១ ដល់ ថ្ងៃទី ៩ មានតួលេខតែមួយខ្ទង់ គឺខ្ទង់រាយចាប់ពីថ្ងៃទី១០ ដល់ ៣១ មានពីរ ខ្ទង់រាយ និងខ្ទង់ដប់ ។ លេខមួយខ្ទង់របស់ថ្ងៃចាប់ពី ១ រហូតដល់ ៩ ចាំបាច់ត្រូវតែបន្ថែមសូន្យនៅខាងដើម ធ្វើបែបនេះដើម្បី ចៀសវាងការបន្លំបន្ថែមលេខផ្សេងទៀតនៅខាងដើមនៃលេខនោះដោយយើងមិនបានបន្ថែមសូន្យ ដើម្បីអោយបានពីរខ្ទង់ដូច ជាលួចបន្ថែមលេខ ១ ឬ ២ទៅលើថ្ងៃទី ៩ ទៅជាបានថ្ងៃទី ១៩ ឬ ២៩ ទៅវិញ ។

ចំពោះការបន្ថែមសូន្យទៅលើខែមីនាពិតជាមិនត្រឹមត្រូវទេ យើងមិនបាច់បន្ថែមសូន្យនៅខាងដើមនៃលេខ ៣ របស់ខែ មីនាទេ ព្រោះក្នុងមួយឆ្នាំមានចំនួន១២ខែ បើគេលួចបន្ថែមលេខ ១ ឬ ២ ទៅលើខែមីនានោះ យើងគ្មានអ្វីគួរអោយ សង្ស័យឡើយ ព្រោះការបន្ថែម១ ឬ ២នេះ និងក្លាយទៅជាខែ ១៣ ឬខែ ២៣ គឺគ្មានទេខែរបស់ខ្មែរយើង ។ ហេតុនេះ បានជាយើងមិនបាច់បន្ថែមសូន្យលើខែមីនា ។

ក្រៅពីខែមីនា មានខែពីរទៀតដែលយើងចាំបាច់បន្ថែមសូន្យជានិច្ច គឺខែមករា និង ខែកុម្ភៈ ។ ឧបមាថាបើ ក្មេង "ក" កើតថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ១៩៩០ យើងសរសេរត្រឹមតែ ០៤-៦-១៩៩០ បើក្មេង ខ កើតថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩០ ត្រូវសរសេរថា ០៨-០១-១៩៩០ ។

លើសពីនេះទៅទៀត ក្នុងការសរសេរតួលេខជាចំនួនវត្ថុ ឬកំនត់តំលៃផ្សេងៗ លោកគ្រូ អ្នកគ្រូជ្រាបស្រាប់ហើយ គឺគ្មាន អ្វីប្លែកទេ ។

លោក ឈាត ម៉េង គ្រូវិទ្យាល័យ

ដំដែកស្រុកសូទ្រនិគម ខេត្តសៀមរាប




អាគារដ៏ល្អប្រិមប្រិយនៅក្របក្រៅខាងក្រោយនេះ គឺជាផ្ទះគ្រូបង្រៀនដែលត្រូវបានសាងសង់ពី ថ្ងៃទី ១២ ខែ ឧសភា ដល់ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅលើផ្ទៃដីដែលមានបណ្ដោយ ១១៣ម៉ែត្រ និងទទឹង ៤១ម៉ែត្រ ។ នៅលើផ្ទៃដីដែលជាអំណោយរបស់ក្រសួងអប់រំ យុវជន និង កីឡា ដ៏ទូលាយនេះ សមាគមគ្រោង សាងសង់ផ្ទះគ្រូបង្រៀនអោយបានពីរខ្នង ។ ប៉ុន្តែសព្វថ្ងៃនេះ សមាគមសាងសង់អាគារបានរួច១ខ្នង មានបណ្ដោយ ៤១ម៉ែត្រ និងទទឹង ១១ម៉ែត្រ មាន ៣២ បន្ទប់ ។ ក្នុងបន្ទប់នីមួយៗមានគ្រែពីរ តុសរសេរមួយ កៅអីពីរ កូនទូក្បាលគ្រែមួយ បន្ទប់អនាម័យ និងទូដាក់ខោអាវមួយ ។

សំណង់អាគារ គ្រឿងសង្ហារិមបំពាក់អោយបន្ទប់ទាំង ៣២ ព្រមទាំងអណ្ដូងទឹកស្អុប របង.....ល.....ត្រូវ ចំណាយអស់ទឹកប្រាក់សរុបចំនួនមួយរយហាសិបប្រាំបួនពាន់ ប្រាំមួយរយកៅសិបប្រាំបួន ដុល្លាសហរដ្ឋអាមេរិច ( ១៥៩.៦៩៩ $US ) ដែលជា÷

- ព្រះរាជអំណោយសម្ដេចឪ និងព្រះរាជអគ្គមហេសី : ៣.០០០ $US
- អំណោយសម្ដេច ហ៊ុន សែន និងលោកជំទាវ : ៤០.០០០ $US
- ថវិកាផ្ទាល់របស់សមាជិក សមាជិកា : ១១៦.៦៩៩ $US

ក្រៅពីអំណោយនេះ សមាគមក៏បានទទួលពីសប្បុរសជននូវអំណោយជាគ្រឿងអសង្ហារិម និងសង្ហារិមដែល យើងសូមថ្លែងអំណរគុណ និងសូមអភ័យទោសដែលពុំបានលើកឡើងនៅពេលនេះ ។

ឆ្លៀតឱកាសនេះផងដែរ យើងសូមជំរាបថា÷

- ផ្ទះគ្រូបង្រៀននៅរាជធានីភ្នំពេញ មាន ១៦ បន្ទប់ ថ្លៃស្នាក់ក្នុង១បន្ទប់ ១០.០០០រៀល
- ផ្ទះគ្រូបង្រៀននៅខេត្តកំពត មាន ១៤ បន្ទប់ ថ្លៃស្នាក់ក្នុង១បន្ទប់ ១២.០០០រៀល
- ផ្ទះគ្រូបង្រៀននៅខេត្តសៀមរាប មាន ៣២ បន្ទប់ ថ្លៃស្នាក់ក្នុង១បន្ទប់ ១៤.០០០រៀល

ថ្លៃស្នាក់នៅមានការខុសគ្នា អាស្រ័យលើថ្លៃទឹក ភ្លើងនៅទីតាំងពាក់ព័ន្ធនីមួយៗ ។

# តើអ្នកគ្រូ លោកគ្រូ ដឹងឬទេ ?

| + តើប្រទេសណា មានផ្ទៃដីធំជាងគេ ? | |
|---|---|
| ឈ្មោះប្រទេស | ទំហំផ្ទៃដី |
| - រុស្ស៊ី | ១៧.0៧៥.000 $Km^2$ |
| - កាណាដា | ៩.៩៧៥.000 $Km^2$ |
| - ចិន | ៩.៦00.000 $Km^2$ |
| - សហរដ្ឋអាមេរិក | ៩.៣៦៤.000 $Km^2$ |
| - ប្រេស៊ីល | ៧.៥១២.000 $Km^2$ |

| + តើប្រទេសណា មានផ្ទៃដីតូចជាងគេ ? | |
|---|---|
| ឈ្មោះប្រទេស | ទំហំផ្ទៃដី |
| - វ៉ាទីកង់ | 0.៤៤ $Km^2$ |
| - ម៉ូណាកូ | ២ $Km^2$ |
| - ណាអ៊ូរូ | ២១ $Km^2$ |
| - ទូវ៉ាលូ | ២៤ $Km^2$ |
| - សាំងម៉ារ៉ាំង | ៦១ $Km^2$ |

| + តើប្រទេសណា មានប្រជាជនច្រើនជាងគេ ? | |
|---|---|
| ឈ្មោះប្រទេស | ចំនួនប្រជាជន |
| - ចិន | ១.២៣៤.៣៣៧.000នាក់ |
| - ឥណ្ឌា | ៩៥២.៩៦៩.000នាក់ |
| - សហរដ្ឋអាមេរិក | ២៦៥.៧៦៥.000នាក់ |
| - ឥណ្ឌូនេស៊ី | ២00.៥៩៦.000នាក់ |
| - ប្រេស៊ីល | ១៦៤.៤២៤.000នាក់ |

| + តើប្រទេសណា មានប្រជាជនតិចជាងគេ ? | |
|---|---|
| ឈ្មោះប្រទេស | ចំនួនប្រជាជន |
| - វ៉ាទីកង់ | ១.000 នាក់ |
| - ទូវ៉ាលូ | ១0.000 នាក់ |
| - ណាអ៊ូរូ | ១១.000 នាក់ |
| - ប៉ាឡូវ | ១៧.000 នាក់ |
| - សាំងម៉ារ៉ាំង | ២៥.000 នាក់ |

+ប្រទេសកម្ពុជាយើង ស្ថិតក្នុងលំដាប់ទីប៉ុន្មាន ក្នុងចំណោមរដ្ឋឯករាជ្យទាំង ១៩២ ក្នុងលោកយើងនេះ ?

- បើគិតពីផ្ទៃដី (១៨១.0៣៥ គម២) លំដាប់ទី ៨៧ ។
- បើគិតពីប្រជាជន (១១.៥២៦.២២៣ នាក់) * លំដាប់ទី ៧២ ។

**ប្រភពពត៌មាន**

*Larousse encyclopédique 2001*

* ស្ថិតិជំរឿន ឆ្នាំ ១៩៩៨

**ស.ប.ស.ខ**

# ស្ថិតិសពចាប់ពីឆ្នាំ ១៩៩៥
## ដល់ដំណាច់ខែធ្នូ ឆ្នាំ២០០២

| ល.រ | ខេត្ត-ក្រុង | សពសមាជិក | សពគូស្រករ ប្ដីឬប្រពន្ធ | ផ្សេងៗ |
|---|---|---|---|---|
| ០១ | អង្គភាពចំនុះក្រសួង អ.យ.ក | ១៤៧នាក់ | ៥៧នាក់ | |
| ០២ | រាជធានីភ្នំពេញ | ២៣៥នាក់ | ១៨៧នាក់ | |
| ០៣ | កំពង់ចាម | ៣៩៤នាក់ | ២៥៩នាក់ | |
| ០៤ | កំពង់ធំ | ១៤៩នាក់ | ១០៨នាក់ | |
| ០៥ | កំពង់ស្ពឺ | ១៧០នាក់ | ១១២នាក់ | |
| ០៦ | កំពង់ឆ្នាំង | ១០៣នាក់ | ៥៧នាក់ | |
| ០៧ | កណ្ដាល | ២៨៧នាក់ | ១៨៧នាក់ | |
| ០៨ | កំពត | ១៤០នាក់ | ១១៣នាក់ | |
| ០៩ | កោះកុង | ១៨នាក់ | ១១នាក់ | |
| ១០ | ក្រុងកែប | ០៣នាក់ | ០៥នាក់ | |
| ១១ | ក្រុងព្រះសីហនុ | ៥០នាក់ | ២៧នាក់ | |
| ១២ | ក្រចេះ | ៦៧នាក់ | ៦២នាក់ | |
| ១៣ | តាកែវ | ២៣៧នាក់ | ១៤២នាក់ | |
| ១៤ | បាត់ដំបង | ២១៦នាក់ | ១៥៣នាក់ | |
| ១៥ | ព្រៃវែង | ២៧៧នាក់ | ១៨៨នាក់ | |
| ១៦ | បន្ទាយមានជ័យ | ១៥៧នាក់ | ១០៥នាក់ | |
| ១៧ | ព្រះវិហារ | ៣១នាក់ | ២២នាក់ | |
| ១៨ | សៀមរាប | ១៨៤នាក់ | ១៣៥នាក់ | |
| ១៩ | ប៉ៃលិន | ០៥នាក់ | ០០នាក់ | |
| ២០ | ស្វាយរៀង | ១៣៧នាក់ | ៨៦នាក់ | |
| ២១ | ពោធិសាត់ | ៧៩នាក់ | ៥៣នាក់ | |
| ២២ | ស្ទឹងត្រែង | ១៦នាក់ | ១៦នាក់ | |
| ២៣ | រតនគីរី | ១១នាក់ | ០៧នាក់ | |
| ២៤ | មណ្ឌលគីរី | ១០នាក់ | ០១នាក់ | |
| ២៥ | ឧត្ដរមានជ័យ | ០៣នាក់ | ០១នាក់ | |
| | **សរុប** | **៣.១២៦នាក់** | **២.០៩៤នាក់** | |